# កឋិនកថាសង្ខេប

## វិនយបិដក

## ១៧

ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស ២៥៣៩

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# កឋិនកថាសង្ខេប


រៀបរៀងដោយ

សម្តេចព្រះពោធិវង្ស (វជិរប្បញ្ញោ) ហួត-តាត

ជួយពិនិត្យផ្ទៀងផ្ទាត់ដោយ

សម្តេចព្រះមហាសុមេធាធិបតី ( ជ. ណ. ជោតញ្ញាណោ ) ព្រះសង្ឃរាជថ្នាក់ទី ១

វត្តឧណ្ណាលោម ក្រុងភ្នំពេញ



បោះពុម្ពគ្រាទី ១

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥១៣ គ. ស. ១៩៦៩

# សេចក្ដីបញ្ជាក់
# ចំពោះការបោះពុម្ពផ្សាយឡើងវិញ

សៀវភៅនេះ ត្រូវបានបោះពុម្ពជាថ្មីឡើងវិញ ដោយមានការឧបត្ថម្ភពីអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC) និងពីអង្គការ រិស្សូ កូសី-កៃ (RKK) ។

ការបោះពុម្ពឡើងវិញលើកនេះ ធ្វើឡើងដោយថតចម្លងពីសៀវភៅច្បាប់ដើមទាំងស្រុង ។ ហេតុនេះ ប្រសិនបើមានកំហុសអក្ខរាវិរុទ្ធក្ដី កំហុសក្នុងការរៀបរៀងឃ្លាក្ដី នោះគឺជាលក្ខណៈដែលមានក្នុងច្បាប់ដើមពីមុនមក ។

ពុទ្ធសាសនបណ្ឌិត្យ សូមអភ័យទោសជាមុន ចំពោះកង្វះខាតផ្សេងៗ ដែលអាចនឹងកើតមានដោយអចេតនា ក្នុងការបោះពុម្ពឡើងវិញនេះ ។

ពុទ្ធសាសនបណ្ឌិត្យ នឹងខិតខំចាត់ការបោះពុម្ពសៀវភៅសិក្សា និងសៀវភៅអានគ្រប់បែបយ៉ាងផ្សេងទៀត ដើម្បីតម្រូវទៅតាមការចាំបាច់ប្រើប្រាស់របស់សាធារណជនផង ដើម្បីរក្សាមរតកវប្បធម៌ អក្សរសាស្ត្រ អោយគង់វង្សនិងរីកចំរើនផង ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអង្គការជំនួយសូត្តូស៊ូជប៉ុន (JSRC) និងអង្គការ រិស្សូ កូសី-កៃ (RKK) ដែលបានផ្ដល់ការឧបត្ថម្ភដ៏ឧត្ដុង្គឧត្ដមដល់ការបោះពុម្ពសៀវភៅនេះ ។

ភ្នំពេញ, ខែ កញ្ញា ឆ្នាំ ១៩៩៥

ពុទ្ធសាសនបណ្ឌិត្យ

## ごあいさつ

この本は、立正佼成会と曹洞宗国際ボランティア会との共同プロジェクトとして印刷されました。

この本が、日本の仏教徒とカンボジアの人々との友情のきずなとなり、カンボジアの文化発展に貢献できれば幸いです。

## និវេទនកថា

សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយអង្គការជំនួយសូតូស៊ូជប៉ុន ( JSRC ) និងដោយមានការឧបត្ថម្ភពី

អង្គការ រិស្សូ កូសី-កៃ (RKK)

យើងអធិដ្ឋាន សូមអោយសៀវភៅនេះបានជាវិភាគទានរក្សាមិត្តភាពជាមួយប្រជាជនកម្ពុជា និងថែរក្សាសម្បត្តិសាសនា និងសម្បត្តិវប្បធម៌របស់ប្រជាជនកម្ពុជា ។

## ACKNOWLEDGEMENT

This book has been printed by Japan Sotoshu Relief Committee (JSRC) with the contribution from

Rissho Kosei-Kai (RKK)

We pray that this book would contribute to the friendship with Cambodian people and their religious and cultural preservation.

# ពាក្យខុសប្ដូរកែឲ្យត្រូវវិញ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ព្រះពុទ្ធបិត្តា | ព្រះពុទ្ធបិន្តា | ២ | ៥ |
| គឺតាំងពីថៃ ១ កេប | គឺតាំងពីថ្ងៃ ១ កេប | ៨ | ៥ |
| ភក្ខុដទៃ | ភិក្ខុដទៃ | ៨ | ១៤ |
| អធដ្ឋាន | អធិដ្ឋាន | ៥១ | ១៧ |

ក្រសួងធម្មការ ខេត្តបាត់ដំបង ថ្ងៃព្រហស្បតិ៍
១៤កើត ខែជេស្ឋ ឆ្នាំរោង ទោស័ក ពុទ្ធសករាជ ២៥៤៤
ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំយេស៊ូ ២០០០.

សមណសិស្ស ផលបុត្តត្ថេរ សាន ភារ៉េត.

# កឋិនកថាសង្ខេប

## បុព្វហេតុនៃកឋិន

**សួរ**: កឋិនចីវរ កើតមានពីក្នុងសម័យណាមក ?

**ឆ្លើយ** : កើតមានតាំងពីក្នុងសម័យពុទ្ធកាល គឺព្រះសម្មាសម្ពុទ្ធទ្រង់បានអនុញ្ញាតនូវកឋិនចីវរ ដោយព្រះអង្គឯង ។

**ស**. ចុះកឋិនចីវរ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យមានឡើងដោយមានបុព្វហេតុ (ហេតុដើម) ដូចម្ដេចខ្លះ ?

**ឆ**. ដោយមានបុព្វហេតុ ដូចតទៅនេះ គឺមានភិក្ខុ ៣០ រូបនៅក្នុងដែនបាវេយ្យៈ ធ្វើដំណើរទៅកាន់ក្រុងសាវត្ថី ដើម្បីក្រាបថ្វាយបង្គំគាល់ព្រះសម្ពុទ្ធ ដែលគង់នៅក្នុងវត្តព្រះជេតពន, នៅក្នុងពេលចេញវស្សាដែលជារដូវនៅមានទឹកភ្លៀងជោកជាំ នាំឲ្យភិក្ខុ ៣០ រូបនោះមានស្បង់ចីពរ សង្ឃាដីទទឹកជោកអស់ មានការលំបាកតាមផ្លូវយ៉ាងខ្លាំង ។ លុះទៅដល់ ភិក្ខុទាំង ៣០ រូប ក៏បានចូលទៅក្រាបថ្វាយបង្គំព្រះសម្ពុទ្ធ ។ នៅពេលនោះ ព្រះសម្ពុទ្ធ ព្រះអង្គមានព្រះបន្ទូលស្រាយត្រាស់សួរអំពីសុខ-ទុក្ខចំពោះភិក្ខុទាំង ៣០ រូបនោះ ហើយព្រះអង្គបានជ្រាបពីសេចក្ដីលំបាកខ្លាំង ក្នុងការធ្វើដំណើរមកនៃភិក្ខុទាំងនោះ រួចព្រះអង្គសម្ដែងនូវធម្មីកថា នាំឲ្យភិក្ខុទាំង ៣០ រូបនោះបានសម្រេចព្រះអរហត្តផលគ្រប់អង្គ ។

លំដាប់ពីនោះមក ព្រះសម្ពុទ្ធទ្រង់មានព្រះពុទ្ធចិន្ដាថា "ប្រសិន-បើតថាគតបានអនុញ្ញាតនូវកឋិនត្ថារកិច្ច ដល់ភិក្ខុទាំងឡាយរូបហើយ ភិក្ខុ

តាំង ៣០ រូប នេះនឹងអាចទុកចីវរ ១ នៅកន្លែងរបស់ខ្លួន ហើយមកដោយមានតែស្បង់ ១ ចីពរ ១ ប៉ុណ្ណោះ នឹងមិនលំបាកតាមផ្លូវយ៉ាងនេះឡើយ រីឯកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ក៏ធ្លាប់តែទ្រង់អនុញ្ញាតមកដែរ” ។

លុះព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធចិត្ត យ៉ាងនេះហើយ ទើបទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុទាំងឡាយ ហើយទ្រង់អនុញ្ញាតនូវកឋិនត្ថារកិច្ច ដល់ភិក្ខុទាំងឡាយថា ៖

**អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ**

“ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយ ដែលនៅចាំ-វស្សារួចហើយ ទទួលក្រាលកឋិនបាន; ម្នាលភិក្ខុទាំងឡាយ, អានិសង្ស ៥ ប្រការ នឹងសម្រេចដល់ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនរួចហើយ” ។

សេចក្តីសង្ខេបខាងលើនេះ ជាបុព្វហេតុនៃកឋិន ។

## អានិសង្ស ៥

សំ. អ្វីជាអានិសង្ស ៥ ? ចុះអានិសង្ស ៥ នោះ តើនឹងសម្រេចដល់

ភិក្ខុទាំងឡាយ ដែលបានក្រាលកឋិនរួចហើយ ដូចម្ដេចខ្លះ ?

ឆ. ការរំលស់កំហុសក្នុងសិក្ខាបទខ្លះ ឲ្យភិក្ខុបានធូរស្រួលផង ឲ្យភិក្ខុបានលាភដោយងាយផង ហៅថា អានិសង្ស ៥ របស់ភិក្ខុ ។ ឯអានិសង្ស ៥ នោះគឺ **អនាមន្តចារោ ១ អសមាទានចារោ ១ គណភោជនំ ១ យាវទត្ថចីវរំ ១ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ ១** រួមជា ៥ ។

អធិប្បាយនូវអានិសង្សទាំង ៥ ប្រការ ដូចមានតទៅនេះ ៖

## ទី ១ អនាមន្តចារោ

អានិសង្សទី ១ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាលអនុមោទនាកឋិនរួចចាកអាបត្តិក្នុងចារិត្តសិក្ខាបទទី ៦ ក្នុងអចេលកវគ្គនៃសុទ្ធិកបាចិត្តិយៈបាន ។ ក្នុងអដ្ឋកថា មានសេចក្ដីពន្យល់ថា[១] កឋិននៅមិនទាន់ដោះដរាបណា ការដែលភិក្ខុមិនបានលាភិក្ខុផងគ្នាសិន ហើយត្រាច់ទៅ នឹងគួរ គឺថានឹងមិនមានអាបត្តិក្នុងចារិត្តសិក្ខាបទ ដរាបនោះ ។

ក្នុងគម្ពីរធម្មសម្ពុហវិន័យ[២] បានបំពេញសេចក្ដីថែមទៀតថា ការដែលភិក្ខុបានទទួលនិមន្តទាយក ដោយភោជនណាមួយក្នុងភោជនទាំង ៥ រួចហើយ មិនបានលាភិក្ខុផងគ្នាដែលមាននៅក្នុងទីនោះសិន ហើយ

---

១ អនាមន្តចារោតិ យាវ កឋិនំ ន ឧទ្ធរិយតិ តាវ អនាមន្តេត្វា ចរណំ កប្បិស្សតិ ចារិត្តសិក្ខាបទេ អនាបត្តិ ភវិស្សតីតិ អត្ថោ ។ ២ ធម្មសម្ពុហវិន័យនេះជា បករណពិសេស នៃព្រះវិន័យ ជាគម្ពីរកើតមានក្នុងបច្ឆាកាល ប៉ុន្តែមានអត្ថន័យគួរផល់អ្នកសិក្សាវិន័យដែរ ។

ត្រាច់ទៅក្នុងត្រកូលតាំងឡាយ យ៉ាងនេះហៅថា **អនាមន្តចារោ** ។

ក្នុងគម្ពីរវិនយាលង្ការដីកា (១) ថា "ការត្រូវអាបត្តិបាចិត្តិយៈ ដោយចារិត្តសិក្ខាបទ មិនមានដល់ភិក្ខុដែលបានក្រាលកឋិនឡើយ" ។

## ទី ២ អសមាទានចារោ

អានិសង្សទី ២ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចចាកអាបត្តិក្នុងទុតិយកឋិនសិក្ខាបទទី ២ ក្នុងចីវរវគ្គ នៃនិស្សគ្គិយបាចិត្តិយៈបាន ។ ក្នុងអដ្ឋកថាពន្យល់សេចក្តីថា (២) ការដែលភិក្ខុមិនបានកាន់យកនូវត្រៃចីវរ " ចីវរ ៣ " គឺស្បង់ ១ ចីពរ ១ សង្ឃាដី ១ ហើយត្រាច់ទៅ ហៅថា **អសមាទានចារោ** បានសេចក្តីថា ការនៅប្រាសចាកចីវរ ទីងគួរ គឺជាទីងមិនមានអាបត្តិឡើយ ( ដល់ភិក្ខុដែលបានក្រាល-អនុមោទនាកឋិន ) ។

ក្នុងគម្ពីរធម្មសម្ពហវិន័យ ពន្យល់សេចក្តីកាន់តែច្បាស់ថែមទៀតថា ការដែលភិក្ខុមិនបានកាន់យកនូវចីវរ ៣ ដែលខ្លួនបានអធិដ្ឋានហើយ ហើយត្រាច់ទៅ ហៅថា **អសមាទានចារោ** បានសេចក្តីថា ការដែលភិក្ខុទុកចីវរ ៣ ដែលខ្លួនអធិដ្ឋានតាមឈ្មោះហើយ, ចីវរណាមួយ, ក្នុងទីណាមួយ ហើយត្រាច់ទៅញុំាងអរុណឲ្យរះឡើងក្នុងទីឯទៀត ។

---

១ វិនយាលង្ការនេះ ជាដីកាវិនយសង្គហៈ គឺជាដីកានៃគម្ពីរបាលីមុត្តក វិនយវិនិច្ឆ័យ ជាបករណពិសេស ព្រោះជាគម្ពីរកើតមានក្នុងបច្ឆាកាលដែរ ។ ២ អសមាទានចារោតិ តិចីវរំ អសមាទាយ ចរណំ, ចីវរវិប្បវាសោ កប្បិស្សតីតិ អត្ថោ ។

ក្នុងគម្ពីរវិនយាលង្ការដីកា មានសេចក្ដីបន្ថែមថា ការដែលភិក្ខុវៀរបង់នូវត្រៃចីវរណាមួយក្ដី ទាំងអស់ក្ដី មិនធ្វើឲ្យនៅក្នុងហត្ថបាស ហើយញ៉ាំងអរុណឲ្យរះឡើង ហៅថានៅប្រាសចាកចីវរ ។ ភិក្ខុអ្នកក្រាល-អនុមោទនាកឋិនហើយ ទុកជាធ្វើយ៉ាងនេះ ក៏មិនត្រូវអាបត្តិដោយទុតិយ-កឋិនសិក្ខាបទឡើយ ។

## ទី ៣ គណភោជនំ

អានិសង្សទី ៣ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចចាកអាបត្តិក្នុងគណភោជនសិក្ខាបទទី ២ ក្នុងភោជនវគ្គ នៃសុទ្ធិ-កបាចិត្តិយៈបាន ។ ក្នុងអដ្ឋកថា ថា (១)គណភោជន និងគួរ គឺថាមិនមានអាបត្តិឡើយ (ដល់ភិក្ខុដែលបានក្រាល-អនុមោទនាកឋិន) ។

ក្នុងមហាវគ្គ និងក្នុងគម្ពីរផ្សេង ៗ ដែលនិយាយពីគណភោជនមានសេចក្ដីពន្យល់ថា ភិក្ខុទាំងឡាយ៤រូបឡើងទៅដែលទាយកគេនិមន្ត ដោយភោជន៥, ភោជនណាមួយ, ទទួលនូវភោជនណា ភោជននោះហៅថា **គណភោជន** ។ គណៈក្នុងទីនេះ សំដៅយកភិក្ខុ ៤ រូប ឬច្រើនជាង ៤ រូបឡើងទៅ ។ សរុបសេចក្ដីថា ការដែលភិក្ខុទាំងនោះទទួលភោជន៥ មានបាយជាដើម, ភោជនណាមួយ, ក្នុងទីជាមួយគ្នា ដោយការសូមខ្លួនឯងក្ដី ដោយការនិមន្តរបស់ទាយកក្ដី ហៅថា **គណភោជន** ។ ការ

---

១ គណភោជនន្តិ គណភោជនម្បិ កប្បិស្សតិ ។

ដែលភិក្ខុសូមគេថា "ចូរអ្នកប្រគេនបាយដល់អាត្មាទាំងឡាយ" ដូច្នេះក្តី តាយកគេនិមន្តដោយអកប្បិយវោហារថា "សូមលោកទាំងឡាយទទួលបាយរបស់យើងខ្ញុំ" ដូច្នេះក្តី ហើយភិក្ខុ ៤ រូប ឬច្រើនជាង ៤ រូប ទៅទទួលបាយនោះជាមួយគ្នាយកមក ទោះឆាន់ភោជននោះក្នុងទីជាមួយគ្នាក្តី ឆាន់ក្នុងទីផ្សេងគ្នាក្តី ហៅថា **គណភោជន** ។ ព្រោះសិក្ខាបទនេះហាមត្រង់ការទទួលព្រមគ្នា ។ សម្រេចសេចក្តីថា អានិសង្សទី ៣ នេះ អាចធ្វើឲ្យភិក្ខុអ្នកក្រាល-អនុមោទនាកឋិន រួចចាកអាបត្តិ ដោយគណ-ភោជនសិក្ខាបទបាន ។

## ទី ៤ យាវទត្ថចីវរំ

អានិសង្សទី ៤ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន រួចចាកអាបត្តិក្នុងបឋមកឋិនសិក្ខាបទទី ១ ក្នុងចីវរវគ្គ នៃនិស្សគ្គិយ-បាចិត្តិយៈបាន ។ ក្នុងអដ្ឋកថា ថា (១) សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ចីវរចំនួនប៉ុណ្ណោះ ទោះបីមិនបានអធិដ្ឋាន មិនបានវិកប្ប ក៏គួរ គឺថាមិនមានអាបត្តិឡើយ ។

ក្រៅពីអដ្ឋកថា មានគម្ពីរផ្សេងៗជាច្រើន ពន្យល់សេចក្តីឲ្យកាន់តែច្បាស់ឡើងទៀតថា សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ការទ្រទ្រង់ចីវរដែលមិនបានអធិដ្ឋាន មិនបានវិកប្បចំនួនប៉ុណ្ណោះបាន គឺថាទុកដាក់

---

១ យាវទត្ថចីវរន្តិ យាវតកេន ចីវរេន អត្ថោ តាវតកំ អនធិដ្ឋិតំ អវិកប្បិតំ កប្បិ-ស្សតីតិ អត្ថោ ។

ចីវរទាំងនោះឲ្យកន្លង ១០ ថ្ងៃបាន មិនត្រូវអាបត្តិដោយបឋមកឋិនសិក្ខាបទឡើយ ។

## ទី ៥ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ

អានិសង្សទី ៥ នេះ អាចធ្វើឲ្យភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន មានអំណាចទទួលចំណែកលាភ ដែលកើតឡើងក្នុងអាវាសដែលខ្លួនចាំវស្សា ។ ក្នុងអដ្ឋកថាមានសេចក្ដីពន្យល់ថា(១) ចីវររបស់ភិក្ខុសាមណេរដែលធ្វើមរណកាលក្ដី ចីវរដែលគេប្រគេនចំពោះសង្ឃក្ដី ចីវរដែលគេនាំមកដោយទ្រព្យរបស់សង្ឃ ដែលកើតឡើងក្នុងឧបចារសីមានោះក្ដី រួមសេចក្ដីទៅគឺថា ចីវរណាជារបស់សង្ឃ កើតឡើងក្នុងសីមាដែលក្រាលកឋិននោះ ទោះបីកើតឡើងដោយអាការបែបណាក៏ដោយ ចីវរទាំងនោះ នឹងត្រូវបានដល់ភិក្ខុដែលបានក្រាល បានអនុមោទនាកឋិនគ្រប់រូបនោះឯង ។

ក្រៅពីអដ្ឋកថា មានគម្ពីរផ្សេង ៗ ទៀត គឺគម្ពីរវជិរពុទ្ធិដីកា និងធម្មសមូហវិន័យ បានពន្យល់សេចក្ដីបន្ថែមថា ទោះបីភណ្ឌៈដទៃមានបាត្រជាដើម ទាំងសំពត់ដែលសង្ឃចាត់ឲ្យគេប្ដូរដោយអង្ករជាដើម ដែលកើតឡើងក្នុងឧបចារសីមានោះ ឬអង្ករជាដើមដែលសង្ឃចាត់ឲ្យគេប្ដូរដោយ

---

១ យោ ច តត្ថ ចីវរុប្បាទោតិ តត្ថ កឋិនត្ថតសីមាយំ មតកចីវរំ វា ហោតុ សង្ឃំ ឧទ្ទិស្ស ទិន្នំ វា សង្ឃិកេន តត្រុប្បាទេន អាភតំ វា យេន កេនចិ អាការេន យំ សង្ឃិកំ ចីវរំ ឧប្បជ្ជតិ តំ តេសំ ភវិស្សតីតិ អត្ថោ ។

សំពត់វិញ ក៏ត្រូវបានដល់ភិក្ខុដែលបានក្រាល បានអនុមោទនាកឋិន ទាំងនោះដែរ ។

**សំ.** អានិសង្ស ៥ ប្រការខាងលើនេះ ដែលបានសម្រេចដល់ភិក្ខុអ្នកបានក្រាល បានអនុមោទនាកឋិន តើមានរយៈកាលប៉ុន្មាន ?

**ឆ្លើ.** មានរយៈកាល ៥ ខែ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជ ដល់ថ្ងៃ ១៥ កើតខែផគ្គុណ ប៉ុន្តែរយៈកាល ៥ ខែនេះ ចំពោះតែបានក្រាល-អនុមោទនាកឋិន ពីថ្ងៃ ១ រោចខែអស្សុជ ។ ក្នុងរយៈកាល ២៩ ថ្ងៃ គឺពីថ្ងៃ ១ រោចខែអស្សុជ ដល់ថ្ងៃ ១៥ កើតខែកត្តិក ដែលជាកាលនៃកឋិនទាន បើភិក្ខុបានក្រាល-អនុមោទនាកឋិនក្នុងថ្ងៃណា អានិសង្ស ៥ ក៏កើតមានគិតតាំងពីថ្ងៃនោះរហូតដល់ថ្ងៃ ១៥ កើតខែផគ្គុណ ។

**សំ.** ភិក្ខុដែលបានក្រាល-អនុមោទនាកឋិន មានចំនួនច្រើនរូប ។ ចុះបើភិក្ខុ ១ រូប ឬ ២ រូប បានធ្វើឲ្យកឋិនដោះ គឺធ្វើឲ្យអានិសង្សកឋិនរបស់ខ្លួនដាច់អស់ហើយ តើកឋិនរបស់ភិក្ខុដទៃ នឹងដោះទៅតាមគ្នាដែរ គឺឲ្យភិក្ខុដទៃអស់អានិសង្សកឋិនដូចខ្លួនដែរ ឬដូចម្តេច ?

**ឆ្លើ.** ទេ, កឋិនមិនដោះទៅតាមគ្នាទេ បើភិក្ខុណាធ្វើឲ្យកឋិនដោះ ក៏ដោះតែម្នាក់ឯងទៅ អានិសង្ស ៥ របស់ភិក្ខុនោះក៏រលាយអស់តែម្នាក់ឯងទៅ, ចំណែកភិក្ខុឯទៀត ៗ នៅតែមានកឋិន នៅតែមានអានិសង្ស ៥

ដដែល ( រឿងកឋិនដោះនឹងមានសម្ដែងក្នុងមាតិកា ៨ ខាងមុខ ) ។

ស. ប្រសិនបើភិក្ខុអ្នកក្រាល-អនុមោទនាកឋិន ធ្វើឲ្យកឋិនដោះក្នុងថ្ងៃណាមួយ មុនថ្ងៃ១៥ កើតខែផគ្គុណ តើអានិសង្ស ៥ របស់ភិក្ខុនោះនឹងអាចនៅមានរហូតដល់ថ្ងៃ ១៥ កើតខែផគ្គុណដែរឬទេ ?

ឆ. ទេ, អានិសង្ស ៥ នឹងអាចឋិតនៅបាន តែដោយសារកឋិន បើកឋិនដោះក្នុងថ្ងៃណា អានិសង្ស ៥ ក៏អស់ទៅក្នុងថ្ងៃនោះដែរ ។

ស. អានិសង្ស ៥ ដែលបានសួរ-ឆ្លើយរួចមកហើយ ជាអានិសង្សដែលត្រូវមានដល់ភិក្ខុសង្ឃ ដែលបានក្រាល—អនុមោទនាកឋិន ។ ចុះចំណែកពុទ្ធបរិស័ទជាទាយក ដែលជាអ្នកចាត់ចែងធ្វើកឋិនទានយកទៅវេរប្រគេនសង្ឃ ឲ្យក្រាលគ្រងអនុមោទនា តើត្រូវបានទទួលអានិសង្សអ្វីខ្លះដែរ ឬដូចម្ដេច ?

ឆ. ពុទ្ធបរិស័ទជាទាយក ដែលបានធ្វើកឋិនទានវេរប្រគេនសង្ឃ ត្រូវទទួលផលានិសង្សច្រើនណាស់ ជាអានិសង្សដទៃផ្សេងពីអានិសង្ស ៥ របស់ភិក្ខុសង្ឃ ។ ផលានិសង្សនោះ ពុំអាចនឹងនាំយកមកសម្ដែងក្នុងទីនេះបានឡើយ ព្រោះផលានិសង្សនោះទាក់ទងដល់ផ្លូវចិត្ត ដែលមានចែងក្នុងគម្ពីរព្រះសូត្រ មានការទាក់ទងដល់សង្ឃគតា ទក្ខិណាទាន និងកាលទាន ហើយទូលំទូលាយណាស់ផង ។

អានិសង្ស ៥ ចប់

# ពិធីក្រាលកឋិន(១)

ក្នុងកឋិនក្ខន្ធកៈគម្ពីរមហាវគ្គ មានពុទ្ធានុញ្ញាតថា **ឯវញ្ច បន ភិក្ខវេ កឋិនំ អត្ថរិតព្វំ** "ម្នាលភិក្ខុទាំងឡាយ, ភិក្ខុគប្បីក្រាលកឋិនយ៉ាងនេះ" ។

មានគម្ពីរជាច្រើន គឺអដ្ឋកថា ដីកា និងគម្ពីរពិសេសផ្សេង ៗ បានអធិប្បាយពន្យល់អំពីពិធីក្រាលកឋិននេះ និងអំពីលក្ខណការណ៍ផ្សេង ៗ ដែលទាក់ទងនឹងពិធីក្រាលកឋិន ដើម្បីឲ្យភិក្ខុសង្ឃប្រតិបត្តិតាមព្រះពុទ្ធានុញ្ញាតខាងលើនេះ បានដោយប្រពៃ ។

ដូច្នេះតទៅនេះ ខ្ញុំអ្នករៀបរៀងសេចក្ដីនេះ នឹងប្រមូលសេចក្ដីអំពីគម្ពីរទាំងនោះ យកមករួបរួមគ្នា ដោយធ្វើជាពាក្យសួរពាក្យឆ្លើយ ដើម្បីឲ្យលោកអ្នកសិក្សាទាំងឡាយបានងាយយល់ ដូចតទៅនេះ ៖

**ស.** ភិក្ខុមានចំនួនប៉ុន្មានរូប ទើបទទួលក្រាលកឋិនបាន ?

**ឆ.** ភិក្ខុមានចំនួនយ៉ាងតិចបំផុតត្រឹម ៥ រូប ទើបក្រាលកឋិនបានៗ បើតិចជាង ៥ រូប មិនអាចទទួលក្រាលកឋិនបានឡើយ ។ បណ្ដាភិក្ខុទាំង ៥ រូបនោះ យក ៤ រូបជាជំនុំសង្ឃចតុវគ្គ ជាអ្នកប្រគល់សំពត់កឋិន ភិក្ខុ ១ រូបជាអ្នកទទួលក្រាល ។

១ ពាក្យថា ក្រាលកឋិននេះ បាលីថា កឋិនត្ថារ ឬ កឋិនត្ថរណ គឺការបញ្ចេញវាចាឲ្យសង្ឃបានឮច្បាស់រាល់រូបថា ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ ឬថា ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ ឬក៏ថា ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ ។ បើភិក្ខុសង្ឃពុំបានឮច្បាស់រាល់រូបទេ ពុំឡើងជាកឋិនឡើយ គឺភិក្ខុអ្នកក្រាលកឋិននោះត្រូវថាឲ្យឮ ។ បើពុំឮច្បាស់រាល់រូបទេ ត្រូវថាហើយថាទៀត ឲ្យត្រាតែបានឮរាល់រូប ។

ស. ចុះបើមានភិក្ខុច្រើនរូបលើសពីចំនួន ៥ រូបទៅ តើមានកំណត់ចំនួនប៉ុន្មានៗដែរឬទេ ?

ឆ. ឥតមានកំណត់ចំនួនទេ បើទុកជាមានច្រើនដល់ទៅពាន់ហ្មឺនពាន់សែន ក៏គឺតែអាចទទួលក្រាលកឋិនបានដោយប្រពៃណាស់ ។

ស. ចុះភិក្ខុដែលអាចទទួលក្រាលកឋិនបានទាំងនោះ ត្រូវបំពេញករណីយកិច្ចអ្វីជាមុនដែរ ឬក៏គ្មានទេ?

ឆ. មាន, ភិក្ខុដែលអាចទទួលក្រាលកឋិនទាំងនោះ គឺភិក្ខុដែលបានចូលបុរិមិកវស្សា នៅថ្ងៃ ១ រោច ខែអាសាធ ហើយបានបវារណាក្នុងថ្ងៃបឋមបវារណា នៅថ្ងៃ ១៥ កើត ខែអស្សុជ ប៉ុន្តែចំពោះកិច្ចបវារណា ប្រសិនបើមានហេតុភេទណាមួយមកកាំងនាំឲ្យខានបវារណានោះ ក៏មិនជាអ្វីដែរ ឲ្យតែបានចូលបុរិមិកវស្សាក៏អាចទទួលបំពេញកឋិនត្ថារកិច្ចបាន ។

ស. ចុះភិក្ខុដែលមិនបានចូលវស្សា ឬបានចូលវស្សាដែរ ប៉ុន្តែដាច់វស្សា ឬក៏ភិក្ខុដែលចូលបច្ឆិមិកវស្សា នៅថ្ងៃ ១ រោច ខែស្រាពណ៍ភិក្ខុទាំងនេះ អាចទទួលក្រាលកឋិនបានដែរឬទេ ?

ឆ. មិនបានទេ ។

ស. ចុះបើភិក្ខុបានចូលបុរិមិកវស្សាក្នុងវត្តឯទៀត ហើយមកទទួលក្រាលកឋិន រួមជាមួយនឹងភិក្ខុដែលចូលបុរិមិកវស្សាក្នុងវត្តមួយដទៃ តើបានឬទេ ?

ឆ. មិនបានដោយដាច់ខាត ។

ស. ប្រសិនបើភិក្ខុដែលបានចូលបរិវាសកម្ម មិនគ្រប់ចំនួន ៤ រូប យ៉ាងតិច គឺមានតែ ១ រូប ២ រូប ៣ រូប ឬ ៤ រូបប៉ុណ្ណោះ តើត្រូវប្រតិបត្តិដូចម្តេច ដើម្បីឲ្យបានទទួលក្រាលកឋិន ?

ឆ. ត្រូវស្វែងរកភិក្ខុដទៃ មកធ្វើជា គណបូរកៈ បំពេញឲ្យគ្រប់ជាគណៈសង្ឃ មានចំនួន៥រូប ទើបអាចនឹងទទួលក្រាលកឋិនបាន ។ បើមានតែ ១ រូប ឲ្យរក ៤ រូប, បើមាន ២ រូប ឲ្យរក ៣ រូប, បើមាន ៣ រូប ឲ្យរក ២ រូប, បើមាន ៤ រូប ឲ្យរក ១ រូបមកបង្គ្រប់ ឲ្យបានគ្រប់ ៥ រូប យ៉ាងតិច ។

ស. ភិក្ខុដែលត្រូវនិមន្តមកបង្គ្រប់ជាគណបូរកៈនោះ តើភិក្ខុមានលក្ខណៈដូចម្តេច ?

ឆ. ភិក្ខុដែលមិនបានចូលវស្សាក្តី ចូលវស្សាហើយដាច់វស្សាក្តី ចូលបច្ឆិមិកវស្សាក្តី ភិក្ខុនៅក្នុងវត្តដទៃក្តី ក៏អាចនិមន្តមកធ្វើជាគណបូរកៈបានទាំងអស់ ។

ស. ចុះភិក្ខុទាំងប៉ុន្មាន ដែលគេនិមន្តមកធ្វើជាគណបូរកៈនោះ តើត្រូវបានទទួលសង្ឃលាភដែរឬទេ ?

ឆ. មិនត្រូវទទួលសង្ឃលាភទេ, ភិក្ខុទាំងប៉ុន្មានរូបដែលនិមន្តមកធ្វើជាគណបូរកៈនោះ មានភារៈត្រឹមតែជួយបង្គ្រប់ជាគណៈសង្ឃ ស្ត្រ

ញត្តិទុតិយកម្មវាចា ប្រគល់សំពត់កឋិនដល់ភិក្ខុដែលត្រូវក្រាលកឋិនតែប៉ុណ្ណោះ ហើយនិមន្តទៅវិញចុះ ។ ប៉ុន្តែ ភិក្ខុដែលនិមន្តមកធ្វើជាគណបូរកៈនោះ អាចទទួលចង្ហាន់ ឬក៏ទទួលភេសជ្ជៈបាន ក្រៅពីនោះ នឹងអនុមោទនាយកអានិសង្ស ៥ ពុំបានទេ នឹងទទួលយកអានិសង្សលាភ គឺចីវរ ឬសំពត់សាដក ជាសំពត់ដទៃក្រៅពីកឋិនចីវរ ដែលហៅថាកឋិនានិសង្សនោះ ពុំបានឡើយ[១] ។

សំ. ចុះបើក្នុងវត្ត ១ មានភិក្ខុតែ ៤ រូបចូលបុរិមិកវស្សា សាមណេរមាន ១ រូប អាយុគ្រប់ ២០ ឆ្នាំ បានចូលបុរិមិកវស្សាដែរ បើសាមណេរនោះបានឧបសម្បទក្នុងបច្ឆិមិកវស្សា តើភិក្ខុថ្មីនោះដែលមិនទាន់ទាំងបាន ១ វស្សាផង អាចធ្វើជាគណបូរកៈបានឬទេ ?

ឆ. ភិក្ខុថ្មីនោះ ទោះបីបានទទួលឧបសម្បទមិនបាន ១ វស្សាក៏ដោយ អាចធ្វើជាគណបូរកៈក៏បាន ហើយថែមទាំងបាននូវអានិសង្សកឋិនផងទៀត ព្រោះបានចូលបុរិមិកវស្សាតាំងពីសាមណេរមកហើយ ។ ដោយអាស្រ័យហេតុនេះ បានជាព្រះសព្វញ្ញូទ្រង់អនុញ្ញាតឲ្យសាមណេរចូលវស្សា ទោះសាមណេរតូច ៗ ដែលមានអាយុ ៧ ឆ្នាំក៏ដោយ ត្រូវតែចូលវស្សា ប៉ុន្តែគ្មានពិធីបវារណាចេញវស្សាដូចភិក្ខុទេ ។

---

១ តាមមតិរបស់ខ្ញុំយល់ថា បើទាយកគេធ្វើទេយ្យទានដោយឡែកផ្សេង ក្រៅអំពីសង្ឃលាភដែលគេវេរប្រគេនសង្ឃក្នុងកឋិនាភិសនោះ ដើម្បីប្រគេនចំពោះលោកជាគណបូរកៈនោះផង ដោយសេចក្ដីជ្រះថ្លារបស់គេ លោកជាគណបូរកៈទាំងនោះ ក៏អាចទទួលទេយ្យទានទាំងនោះបាន ឥតខុសអ្វីទេ ។

សាមណេរដែលបានឧបសម្បទជាភិក្ខុថ្មី ហើយអាចធ្វើជាគណបូរកៈនោះ មិនមែនត្រឹមតែ ១ រូបប៉ុណ្ណោះទេ បើភិក្ខុមាន ៣ រូប ត្រូវបញ្ចូលសាមណេរជាភិក្ខុថ្មី ២ រូប, បើភិក្ខុមាន ២ រូប ត្រូវបញ្ចូលសាមណេរជាភិក្ខុថ្មី ៣ រូប, បើភិក្ខុមានតែ ១ រូប ត្រូវបញ្ចូលសាមណេរជាភិក្ខុថ្មី ៤ រូប ឲ្យតែបានគ្រប់ ៥ រូប តែត្រូវរើសយកសាមណេរដែលមានអាយុគ្រប់ ២០ ឆ្នាំ ហើយបានចូលបុរិមិកវស្សាផង មកឲ្យឧបសម្បទក្នុងបច្ឆិមិកវស្សាផង ហើយបញ្ចូលជាគណបូរកៈបាន ។

សំ. ចុះបើក្នុងវត្ត ១ ភិក្ខុដែលចូលបុរិមិកវស្សាទាំងប៉ុន្មាន មិនឈ្លាសវាងវៃក្នុងការក្រាលកឋិនសោះ តើត្រូវធ្វើដូចម្តេច ?

ឆ. ត្រូវស្វែងរកលោកជាថេរៈ ដែលឈ្លាសវាងវៃក្នុងកិច្ចក្រាលកឋិន ហើយចេះចាំវិន័យកឋិនក្ខន្ធកៈ និមន្តលោកមកឲ្យជួយសូត្រកម្មវាចា ជួយបង្ហាញក្រាលកឋិន គ្រាន់តែបានសម្រេច ។ ប៉ុន្តែព្រះថេរៈទាំងនោះ មិនត្រូវបាននូវអានិសង្សលាភរបស់កឋិនឡើយ ។

សំ. ភិក្ខុដែលគួរដល់ការក្រាលកឋិន ត្រូវឲ្យមានការឈ្លាសវៃក្នុងធម៌អ្វីខ្លះ ?

ឆ. ត្រូវឲ្យមានការឈ្លាសវៃក្នុងធម៌ ៨ ប្រការ ទើបគួរក្រាលកឋិនបាន ដូចក្នុងគម្ពីរវិន័យវិនិច្ឆ័យ លោកនិពន្ធរឿងនេះទុកជាគាថា ថា :

**អដ្ឋធម្មកោវិទោ ភិក្ខុ កឋិនត្ថារមរហតិ**
**បុព្វបច្ចុទ្ធរាធិដ្ឋា- នត្ថារោ មាតិកាបិ ច**
**បលិពោធោ ច ឧទ្ធារោ អានិសំសោ បនដ្ឋិមេ ។**

*ភិក្ខុដែលគួរក្រាលកឋិនបាននោះ ត្រូវជាអ្នកឈ្លាសវៃក្នុងធម៌ ៨ ប្រការគឺ បុព្វករណៈ ១ បច្ចុទ្ធរៈ ១ អធិដ្ឋានៈ ១ អត្ថារៈ ១ មាតិកា ១ បលិពោធ ១ ឧទ្ធារៈ ១ អានិសង្ស ១ នេះជាធម៌ ៨ ប្រការ ។*

*ដូច្នេះ បើភិក្ខុក្នុងវត្ត ឈ្លាសវៃក្នុងធម៌ ៨ ប្រការខ្លួនឯង គប្បីក្រាលកឋិនខ្លួនឯងចុះ បើមិនឈ្លាសវៃទេ ត្រូវស្វែងរកលោកឯទៀតដែលឈ្លាសក្នុងធម៌ ៨ ប្រការនោះ ឲ្យនិមន្តលោកមកឲ្យជួយចាត់ការទើបបាន បើមិនធ្វើយ៉ាងនេះទេ មិនគួរក្រាលកឋិនឡើយ ។ រីឯព្រះថេរៈដែលនិមន្តមកពីក្រៅជាជំនួយនោះ មិនត្រូវក្រាលកឋិនខ្លួនឯងទេ ត្រូវគ្រាន់-តែជួយចាត់ចែងធ្វើនូវកិច្ចគ្រប់យ៉ាងមានបុព្វកិច្ចជាដើម ហើយគប្បីឲ្យភិក្ខុអ្នកនៅក្នុងសីមា ដែលបានចូលបុរិមិកវស្សាទាំងប៉ុន្មាននោះ ក្រាលកឋិន អនុមោទនាកឋិនចុះ ។*

## អំពី កឋិនទាយក “អ្នកប្រគេនសំពត់កឋិន”

សំ. *សំពត់កឋិន តើបុគ្គលប្រភេទណាប្រគេន ទើបគួរ ?*

ឆ. *អដ្ឋកថា ប្រាប់ថា(១) បុគ្គលណាមួយ គឺទេវតាក្តី មនុស្សក្តី*

១ យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ វា សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្តតិ ។

បណ្ដាសហធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរៈ សាមណេរី សហធម្មិកណាមួយក្ដី ប្រគេន គួរទាំងអស់ ។

ស. ចុះកឋិនទាយក "អ្នកប្រគេនសំពត់កឋិន" ត្រូវមានកិច្ចវត្ត យ៉ាងណាដែរឬទេ ?

ឆ. **មាន**, ក្នុងអដ្ឋកថា លោកប្រាប់ថា កឋិនទាយកត្រូវមានកិច្ចវត្តយ៉ាងនេះ គឺថា បើកឋិនទាយកមិនដឹងនូវកិច្ចដែលនឹងធ្វើចីវរនោះទេ ហើយគេសួរភិក្ខុថា "កឋិនត្រូវយើងខ្ញុំប្រគេនដូចម្ដេច ?" ភិក្ខុត្រូវប្រាប់ទៅគេវិញយ៉ាងនេះថា "ត្រូវអ្នកនាំយកនូវសំពត់ឲ្យគ្រប់គ្រាន់ល្មមធ្វើចីវរណាមួយបាន ក្នុងចីវរទាំង ៣ គឺស្បង់, ចីពរ និងសង្ឃាដី ហើយវេរប្រគេនដំនុំសង្ឃដោយពាក្យថា **កឋិនចីវរំ(១) ឥមំ** "យើងខ្ញុំសូមវេរប្រគេន នូវកឋិនចីវរ" ឬវេរថា **ឥមិនា វត្ថេន ឋិនំ អត្ថរតុ** "សូមព្រះភិក្ខុសង្ឃក្រាលនូវកឋិនដោយសំពត់នេះចុះ" ដូច្នេះក៏បាន ក្នុងសម័យដែលអរុណទើបរះ រួចហើយត្រូវអ្នកប្រគេនម្ជុលចំនួនប៉ុណ្ណោះ, ចេសចំនួនប៉ុណ្ណោះ, គ្រឿងជ្រលក់ចំនួនប៉ុណ្ណោះ ដើម្បីបរិកម្មធ្វើចីវរនោះ ក្រៅពីនេះត្រូវអ្នកប្រគេនយាគូនិងភត្ត ដល់ភិក្ខុចំនួនប៉ុណ្ណោះអង្គដែលកំពុងធ្វើបរិកម្ម គឺចាត់ចែងធ្វើចីវរនោះផង ទើបគួរ" ។ (បើកឋិនទាយកគេសួរ សឹមប្រាប់, បើគេមិនសួរ មិនត្រូវប្រាប់ទេ ប៉ុន្តែមិន

១ គួរបន្ថែមបាលីមួយម៉ាត់ថា "សង្ឃស្ស" ត្រង់ចន្លោះនេះ ទើបបានសេចក្ដីល្អ ។

ត្រូវប្រាស្រ័យឲ្យហួសហេតុឡើយ) ។

គម្ពីរធម្មសម្ពហវិន័យ ប្រាប់ពិធីវេរសំពត់កឋិនថា ត្រូវកឋិនទាយក នោះ យកសំពត់កឋិនទៅតម្កល់ក្នុងហត្ថបាសជំនុំសង្ឃ ដែលគង់ឬឈរ ក្នុងវត្តដែលនៅចាំវស្សា ហើយវេរប្រគេនដោយបញ្ចេញវាចាយ៉ាងច្បាស់ ថា “**កឋិនចីវរំ**(១) **ទេម** យើងខ្ញុំសូមវេរប្រគេនទូវចីវរកឋិន” ។

សំ. កាលបើកឋិនទាយក វេរសំពត់កឋិនមក តើសង្ឃត្រូវទទួល ដូចម្ដេច ?

ឆ. តាមគម្ពីរវិនយាលង្ការដីកា ប្រាប់ថា(២) កិច្ចទទួល (ដោយកាយ ឬដោយវាចា) មិនមានទេ, កាលបើទាយកវេរប្រគេនចីវរមក គ្រាន់តែ ទទួលដោយចិត្តរបស់សង្ឃប៉ុណ្ណោះ ក៏យកជាប្រមាណ(៣)បាន ។

សំ. កាលបើសង្ឃបានទទួលសំពត់កឋិនហើយ តើត្រូវប្រតិបត្តិ ដូចម្ដេចតទៅទៀត ?

ឆ. អដ្ឋកថា ប្រាប់ថា កឋិនដែលកើតឡើងត្រឹមត្រូវតាមធម៌ហើយ ត្រូវឲ្យភិក្ខុអ្នកក្រាលទទួលក្រាលចុះ ប៉ុន្តែកាលដែលក្រាលត្រូវដឹងកិច្ចវត្ត

១ គួរបន្ថែមបាលី ១ ម៉ាត់ថា “សង្ឃស្ស” ត្រង់ចន្លោះនេះ ទើបបានសេចក្ដីល្អ ។ ២ បដិគ្គហណកិច្ចំ នត្ថិ ទាយកេន ចីវរេ ទិន្នេ សង្ឃស្ស ចិត្តេន សម្បដិច្ឆិតមត្តមេវ បមាណំ ហោតិ ។ ៣ ក្នុងប្រទេសកម្ពុជាយើងបច្ចុប្បន្ននេះ ព្រះសង្ឃគ្រប់វត្ត កាលដែលទាយកវេរកឋិនចីវររួច មិនដែលទទួលដោយកាយ ឬដោយវាចាទេ គ្រាន់តែបញ្ចេញវាចា ថា “សាធុ” ប៉ុណ្ណោះ ។ ពាក្យថា សាធុ នេះ មិនមែនបានន័យថាទទួលទេ ជាពាក្យឲ្យពរថា សូមឲ្យសម្រេចតាមប្រាថ្នាចុះ ។ ហេតុនេះ ការបញ្ចេញវាចាថាសាធុនោះ ជាការសមរម្យហើយ ។

ផង ព្រោះសំពត់ដែលប្រឡាក់ដោយបាយតម្បាញ គឺសំពត់ថ្មីសុទ្ធក្តី សំពត់ដែលប្រឡាក់ដោយមន្ទិលផ្សេងៗក្តី មិនគួរក្រាលទេ ព្រោះហេតុនោះ កាលបើភិក្ខុបានសំពត់សាដកសម្រាប់ក្រាលកឋិន ជាសំពត់ថ្មីសុទ្ធមកហើយ ត្រូវបោកគក់ឲ្យស្អាត ហើយតាក់តែងគ្រឿងឧបករណ៍សម្រាប់ធ្វើចីវរមានម្ជុលជាដើម ហើយត្រូវដេរជាមួយនឹងភិក្ខុច្រើនរូប ឲ្យហើយស្រេចក្នុងថ្ងៃនោះ ហើយត្រូវជ្រលក់ ធ្វើពិន្ទុកប្ប អធិដ្ឋាន ក្រាលកឋិនចុះ ។

ស. ពាក្យឆ្លើយនេះចំពោះសំពត់កឋិនថ្មីសុទ្ធ ដែលមិនទាន់ធ្វើជាចីវរនៅឡើយ ចុះបើទាយកគេវេរប្រគេនចីវរដែលធ្វើស្រេចហើយ តើត្រូវសង្ឃប្រតិបត្តិដូចម្តេច ?

ឆ. ក្នុងគម្ពីរវជិរពុទ្ធិដីកា ប្រាប់ថា(១) បើទាយកវេរប្រគេនចីវរដែលមានបុព្វករណៈ(២) ធ្វើស្រេចហើយដល់សង្ឃ ត្រូវសង្ឃទទួលហើយប្រគល់ឲ្យទៅភិក្ខុអ្នកក្រាល ដោយកម្មវាចាចុះ ។ ឯភិក្ខុអ្នកក្រាលកឋិននោះសោត ត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះរួចហើយ ត្រូវញុំាងសង្ឃឲ្យអនុមោទនាចុះ ព្រោះមិនមានកិច្ចអ្វីដែលត្រូវធ្វើ ចំពោះចីវរដែលមានបុព្វករណៈដែលគេធ្វើរួចហើយនោះម្តងទៀតទេ ។

---

១ បរិនិដ្ឋិតបុព្វករណមេវ ចេ ទាយកោ សង្ឃស្ស ទេតិ សម្បដិច្ឆិត្វា កម្មវាចាយ ទាតព្វំ ។ តេន ច តស្មិំយេវ សីមមណ្ឌលេ អធិដ្ឋហិត្វា អត្ថរិត្វា សង្ឃោ អនុមោទាបេតព្វោ កតបុព្វករណស្ស បុន កាតព្វាភាវតោ ។ ២ បុព្វករណៈ ៧ គឺ ធោវនៈ បោកគក់, វិចារណៈ ចាត់-ចែងវាស់, ឆេទនៈ កាត់, ពន្ធនៈ ដាន, សិព្វនៈ ដេរ, រជនៈ ជ្រលក់, កប្បៈ ពិន្ទុកប្ប ។

# អំពីភិក្ខុជាអ្នកក្រាលកឋិន

ស. កឋិនត្រូវភិក្ខុរូបណាក្រាល ?

ឆ. ក្នុងអដ្ឋកថា ថា សង្ឃប្រគល់កឋិនចីវរឲ្យទៅភិក្ខុរូបណា ត្រូវភិក្ខុរូបនោះក្រាល ។

ស. ចុះសង្ឃត្រូវប្រគល់កឋិនចីវរឲ្យទៅភិក្ខុរូបណា ?

ឆ. អដ្ឋកថា ប្រាប់ថា ភិក្ខុរូបណាមានចីវរចាស់គ្រាំគ្រា សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុរូបនោះ ។

ស. ចុះបើភិក្ខុដែលមានចីវរចាស់គ្រាំគ្រាមានច្រើនរូប តើសង្ឃត្រូវប្រតិបត្តិដូចម្ដេច ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ដល់ភិក្ខុដែលមានចីវរចាស់គ្រាំគ្រាណាស់ ហើយចាស់វស្សាជាងគេ ។

ស. ចុះបើភិក្ខុចាស់ទាំងនោះ មានច្រើនរូប តើសង្ឃត្រូវធ្វើដូចម្ដេចទៀត ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុចាស់ជាមហាបុរស ដែលមានសមត្ថភាពអាចធ្វើចីវរឲ្យបានសម្រេច បានក្រាលកឋិនក្នុងថ្ងៃនោះ ។

ស. ចុះបើបណ្ដាភិក្ខុចាស់ទាំងនោះ ឥតមានភិក្ខុចាស់រូបណាមួយដែលមានសមត្ថភាពនឹងធ្វើដូច្នោះបាន តើសង្ឃត្រូវធ្វើដូចម្ដេចទៀត ?

ឆ. សង្ឃត្រូវប្រគល់កឋិនចីវរ ឲ្យទៅភិក្ខុខ្ចីជាង ដែលមានសមត្ថ-

កាលអាចនឹងធ្វើចីវរឲ្យសម្រេចបាននោះចុះ ប៉ុន្តែដែលឲ្យសមរម្យនោះ សង្ឃគួរតែសង្គ្រោះចំពោះភិក្ខុជាមហាថេរដែលចាស់ជាងគេ ហើយមានចីវរចាស់គ្រាំគ្រាផង ។ ហេតុនោះសង្ឃគប្បីបង្ខំលោកដែលចាស់ជាងគេឲ្យទទួលដោយពោលថា "សូមឲ្យលោកទទួលចុះ សឹមយើងជួយធ្វើប្រគេន" រួចហើយត្រូវពិនិត្យមើលចីវរប្រក្រតីទាំង ៣ ផ្ទាំងរបស់លោក បើឃើញថាចីវរណាចាស់គ្រាំគ្រាជាងគេ, ត្រូវសូត្រញត្តិប្រគល់សំពត់កឋិនទៅលោក ឲ្យល្មមធ្វើចីវរនោះគ្រាន់, បើចីវរប្រក្រតីរបស់លោកពីរជាន់ ត្រូវប្រគេនលោកឲ្យល្មមធ្វើពីរជាន់បាន, បើចីវរប្រក្រតីរបស់លោកតែ ១ ជាន់ទេតែក្រាស់ ហើយសំពត់កឋិនស្តើង ក៏ត្រូវប្រគេនលោកឲ្យល្មមធ្វើពីរជាន់ដែរ ដើម្បីឲ្យសមគួរដល់ចីវរចាស់របស់លោក, បើទុកជាលោកប្រកែកថា "បើមិនបានពីរជាន់ បានតែមួយជាន់ ក៏ខ្ញុំដណ្តប់ដែរ" ដូច្នេះ ក៏ត្រូវតែប្រគេនសំពត់កឋិនទៅលោក ឲ្យល្មមធ្វើចីវរពីរជាន់បានទើបគួរ ។

សំ. ជំនុំសង្ឃត្រូវប្រគល់សំពត់កឋិន ឲ្យទៅភិក្ខុអ្នកក្រាល ដោយពិធីដូចម្តេច ?

ឆ. ដោយពិធីសូត្រញត្តិទុតិយកម្មវាចា ។ ពិធីសូត្រញត្តិទុតិយ-កម្មវាចានេះ ក្នុងគម្ពីរមហាវគ្គ មានពុទ្ធានុញ្ញាតថាឲ្យភិក្ខុ មួយរូប ដែលឈ្លាសប្រតិពល សូត្រប្រកាសចំពោះសង្ឃថា :

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិន-
ទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ
កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទទេយ្យ កឋិនំ
អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ
ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ
កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។
យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថ-
ន្នាមស្ស ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស
យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន
កឋិនទុស្សំ ឥត្ថន្នាមស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ ខមតិ
សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។

*បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ, បើ (ការណ៍នេះ) ជាការគួរដល់សង្ឃហើយ, សង្ឃគប្បីឲ្យនូវសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន ។ នេះជាពាក្យប្រកាសឲ្យសង្ឃបានជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ, សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ, (ឥឡូវនេះ) សង្ឃឲ្យនូវសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បី*

---

១ ត្រង់ពាក្យថា "ឥត្ថន្នាមស្ស" គ្រប់បទ ត្រូវផ្លាស់យកនាមភិក្ខុអ្នកក្រាលដាក់ជាជំនួស ។ ត្រង់បាលីថា កឋិនទុស្សំ ប្រើជា កឋិនវត្ថំ វិញក៏បាន ។

ក្រាលកឋិន ។ ការឲ្យសំពត់កឋិននេះ ដល់ភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន គួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃបានឲ្យទៅភិក្ខុឈ្មោះនេះហើយ ដើម្បីក្រាលកឋិន, គួរដល់សង្ឃហើយ, ព្រោះហេតុនោះបានជាសង្ឃស្ងៀម, ខ្ញុំចាំទុក នូវ (ការយល់ព្រម) នេះ ដោយតុណ្ហីភាពយ៉ាងនេះ ។

សំ. កាលបើសំពត់កឋិន សង្ឃបានប្រគល់ឲ្យហើយ តើភិក្ខុអ្នកក្រាលត្រូវប្រតិបត្តិដូចម្ដេច ?

ឆ. ក្នុងគម្ពីរបរិវារៈ ប្រាប់ថា ភិក្ខុអ្នកក្រាលកឋិននោះ ត្រូវលាងគក់ ចាត់ចែងវាស់ កាត់ ដេរ ជ្រលក់ ធ្វើពិន្ទុកប្បៈ ឲ្យហើយស្រេចក្នុងថ្ងៃនោះ ហើយក្រាលកឋិនចុះ ។

អដ្ឋកថា ពន្យល់ថា កាលបើសង្ឃប្រគល់សំពត់កឋិនឲ្យយ៉ាងនេះហើយ បើសំពត់កឋិននោះមានបរិកម្ម គេធ្វើរួចស្រេចស្រាប់មកហើយនេះជាការគាប់ប្រសើរហើយ បើសំពត់កឋិនមានបរិកម្មគេមិនទាន់ធ្វើរួចស្រេចនៅឡើយទេ, ភិក្ខុរូបណាមួយអាងថា អញជាថេរៈ ឬអាងថាអញជាពហុស្សុត ហើយមិនជួយធ្វើ ពុំបានឡើយ, ភិក្ខុទាំងអស់ត្រូវតែប្រជុំ

គ្នាជួយបោកគក់ ដេរ ជ្រលក់ ឲ្យហើយស្រេចទើបបាន[១] ។

ក្នុងគម្ពីរវិនយាលង្ការដីកា មានសេចក្ដីពន្យល់នូវពាក្យនៃព្រះអដ្ឋកថាចារ្យខាងលើថា "បើសំពត់កឋិនមានបរិកម្មគេធ្វើរួចស្រេចមកហើយ" នោះឲ្យកាន់តែច្បាស់ថែមទៀតថា ដែលហៅថា «សំពត់កឋិន» មិនមែនបានតែសំពត់សាដកប្រក្រតី គឺសំពត់ថ្មីសុទ្ធប៉ុណ្ណោះទេ ទោះបីសំពត់ជាចីវរដែលមានបុព្វកិច្ចទាំង ៧ ប្រការ គេធ្វើរួចស្រេចហើយ ក៏បានហៅជាសំពត់កឋិនពិតប្រាកដ ។ ព្រោះហេតុនោះ កាលបើទាយកប្រគេនចីវរដែលគេធ្វើរួចស្រេចមកហើយ មិនបាច់ត្រូវការអ្វីនឹងធ្វើបុព្វកិច្ចទាំង ៧ ប្រការទៀតទេ ត្រូវធ្វើកិច្ចទាំងឡាយមានបច្ចុទ្ធរៈ គឺដកចីវរចាស់ជាដើមតែប៉ុណ្ណោះ, ប៉ុន្តែប្រសិនបើមានកិច្ចបន្តិចបន្តួចមិនទាន់សម្រេច ដោយហោចទៅ សូម្បីត្រឹមតែពិន្ទុកប្បៈប៉ុណ្ណោះ ក៏ត្រូវញ៉ាំងកិច្ចនោះឲ្យសម្រេចសិន សឹមធ្វើកិច្ចឯទៀតមានបច្ចុទ្ធរៈ ដកចីវរចាស់ជាដើមនោះចុះ ។

ក្នុងគម្ពីរកង្ខាវិតរណី មានបញ្ជាក់អំពីសំពត់កឋិននេះថា[២] សំពត់កឋិនដែលគេធ្វើរួចស្រេចហើយ កើតឡើង (ដល់សង្ឃ) នុ៎ះជាការល្អមែនពិត ប៉ុន្តែបើសំពត់កឋិននោះ គេដេរដោយពុំបានកាត់ ក៏ត្រឡប់ជាពុំ

---

១ សេចក្ដីក្នុងអដ្ឋកថា ដែលបង្គាប់ឲ្យភិក្ខុទាំងអស់រួមគ្នាជួយធ្វើនេះ ឥតមានបង្គាប់ឲ្យហៅរកគ្រហស្ថជួយធ្វើទេ ។ នេះចំពោះតែសំពត់ដែលពុំទាន់សម្រេចជាចីវរ, ឯសំពត់ដែលទាយកគេធ្វើឲ្យជាត្រៃចីវរស្រេចហើយ ក៏គ្រាន់តែពិនិត្យមើលហើយក្រាលកឋិនចុះ ។ ២ សបេ កតមេវ ឧប្បជ្ជតិ សុន្ទរមេវ អច្ឆិន្នសិព្វិតំ បន ន វដ្ដតិ ។

គួរទៅវិញ (ត្រូវតែរុះដេរជាថ្មីឲ្យត្រឹមត្រូវឡើងទើបក្រាលជាកឋិនកើត) ។

អដ្ឋកថា ប្រាប់ថា ភិក្ខុអ្នកក្រាល ត្រូវទទួលយកចីវរកឋិនដែលធ្វើរួចស្រេច ហើយក្រាលកឋិនតាមវិធីដែលលោកបានពោលក្នុងគម្ពីរបរិវារៈចុះ ។

គម្ពីរវិនយាលង្ការដីកា ពន្យល់ពាក្យក្នុងអដ្ឋកថាខាងលើនេះ ឲ្យកាន់តែច្បាស់លាស់ថែមទៀតថា ភិក្ខុអ្នកក្រាលត្រូវទទួលយកចីវរកឋិនដែលគេធ្វើនូវបុព្វករណៈទាំង ៧ ប្រការគឺ **ធោវនៈ** ការបោកគក់ ១ **វិចារណៈ** ការវាត់វែងវាស់ ១ **ឆេទនៈ** ការកាត់ ១ **ពន្ធនៈ** ការដាំ ១ **សិព្វនៈ** ការដេរ ១ **រជនៈ** ការជ្រលក់ ១ **កប្បៈ** ការធ្វើពិន្ទុកប្បៈ ១ ដែលហៅថាបុព្វកិច្ច រួចសព្វគ្រប់មកហើយនោះ ទៅក្រាលកឋិនចុះ ។

ស. ភិក្ខុអ្នកក្រាល ត្រូវក្រាលកឋិនដូចម្តេច ?

ឆ. ក្នុងអដ្ឋកថា និងក្នុងគម្ពីរបរិវារៈ បានប្រាប់នូវពិធីក្រាលកឋិនថា បើភិក្ខុចង់ក្រាលកឋិនដោយសង្ឃាដី ត្រូវបច្ចុទ្ធរណ៍ដកសង្ឃាដីចាស់របស់ខ្លួនចេញ ហើយអធិដ្ឋានសង្ឃាដីថ្មីឡើង ហើយបញ្ចេញវាចាឲ្យដំនុំសង្ឃបានឮច្បាស់ថា **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** "ខ្ញុំក្រាលកឋិន ដោយសង្ឃាដីនេះ" ។

បើចង់ក្រាលកឋិនដោយឧត្តរាសង្គៈគឺចីពរ ត្រូវបច្ចុទ្ធរណ៍ដកឧត្តរាសង្គៈចាស់របស់ខ្លួនចេញ អធិដ្ឋានឧត្តរាសង្គៈថ្មីឡើង ហើយបញ្ចេញវាចាឲ្យ

ដំនុំសង្ឃបានឮច្បាស់ថា **ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ** "ខ្ញុំក្រាលកឋិន ដោយឧត្តរាសង្គៈនេះ" ។

បើចង់ក្រាលកឋិនដោយអន្តរវាសកៈ គឺស្បង់ ត្រូវបច្ចុទ្ធរ៍ដកអន្តរវា-សកៈចាស់របស់ខ្លួនចេញ អធិដ្ឋានអន្តរវាសកៈថ្មីឡើង ហើយបញ្ចេញវាចាឲ្យដំនុំសង្ឃបានឮច្បាស់ថា **ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ** "ខ្ញុំក្រាលកឋិន ដោយអន្តរវាសកៈនេះ" ។

កាលបើភិក្ខុបានក្រាលកឋិនយ៉ាងនេះរួចហើយ គប្បីចូលទៅជិតសង្ឃ ឬគណៈ ឬក៏បុគ្គល គ្រងចីពរស្មាម្ខាង អង្គុយប្រហោងប្រណម្យអញ្ជលីឡើង ពោលចំពោះសង្ឃ ឬគណៈ ឬក៏បុគ្គលទាំងនោះឲ្យអនុមោ-ទនាថា **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថា-រោ, អនុមោទថ** "បពិត្រលោកដ៏ចម្រើនទាំងឡាយ, កឋិនរបស់សង្ឃខ្ញុំក្រាលរួចហើយ ការក្រាលកឋិននេះប្រកបដោយធម៌, សូមលោកទាំងឡាយអនុមោទនាចុះ" ។

ត្រង់ពាក្យថា **ភន្តេ** បើភិក្ខុអ្នកក្រាលចាស់ជាងភិក្ខុអ្នកអនុមោទ-នាទាំងអស់ ត្រូវផ្លាស់ថា **អាវុសោ** ដូច្នេះវិញ ។ បើភិក្ខុអ្នកអនុមោទនា ចាស់ជាងភិក្ខុអ្នកក្រាល តាំងពី ១ រូបឡើងទៅ ត្រូវថា **ភន្តេ** ដដែល ។

ត្រង់ពាក្យថា **អនុមោទថ** បើភិក្ខុអ្នកអនុមោទនាមានច្រើន

រូប ឬមានតែមួយរូប ប៉ុន្តែចាស់ជាងភិក្ខុអ្នកក្រាល ត្រូវថា **អនុមោ-ទថ** ដដែល ។ បើភិក្ខុអ្នកអនុមោទនា មានតែមួយរូបហើយខ្ចីជាងភិក្ខុអ្នកក្រាល, ត្រូវផ្លាស់ថា **អនុមោទាហិ** ដូច្នេះវិញ ។

ចំណែកភិក្ខុអ្នកអនុមោទនាវិញ ត្រូវគ្រងចីពរស្មាម្ខាង អង្គុយប្រ-ហោង ប្រណម្យអញ្ជលីឡើង អនុមោទនាដោយបញ្ចេញវាចាថា **អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ, ធម្មិកោ កឋិនត្ថារោ, អ-នុមោទាម** ម្នាលលោកអ្នកមានអាយុ, កឋិនរបស់សង្ឃ លោកក្រាលរួចហើយ, ការក្រាលកឋិននេះប្រកបដោយធម៌, យើងទាំងឡាយសូមអនុមោទនា ។

ត្រង់ពាក្យថា **អាវុសោ** សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោ-ទនាចាស់ជាងភិក្ខុអ្នកក្រាល បើភិក្ខុអ្នកអនុមោទនាខ្ចីជាងភិក្ខុអ្នកក្រាល ត្រូវផ្លាស់ថា **ភន្តេ** ដូច្នេះវិញ ។

ត្រង់ពាក្យថា **អនុមោទាម** សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោទនាច្រើនរូបតាំងពីពីររូបឡើងទៅ, បើភិក្ខុអ្នកអនុមោទនាមានតែមួយរូប ត្រូវថា **អនុមោទាមិ** ដូច្នេះវិញ ។

អដ្ឋកថា ប្រាប់ថា(១) កាលបើភិក្ខុមួយរូបជាអ្នកក្រាល ភិក្ខុឯទៀត

---

១ ឯវំ សព្វេសំ អត្ថតំ ហោតិ កឋិនំ ។

ជាអ្នកអនុមោទនាយ៉ាងនេះ ឈ្មោះថាបានក្រាលទាំងអស់គ្នា ។

គន្ថគម្ពីរវិនយាលង្ការដីកា មានសេចក្តីបញ្ជាក់ដោយធ្វើជាពាក្យសួរ-ឆ្លើយ ដូចមានតទៅនេះ ៖

ស. (១) អានិសង្ស ៥ កើតមានដំណាលគ្នានឹងការក្រាលកឋិន តាមន័យដែលមានគន្ថគម្ពីរបរិវារៈថា "ធម៌ ១៥ ប្រការ គឺអានិសង្ស ៥ មាតិកា ៨ និងបលិពោធ ២ កើតដំណាលគ្នានឹងការក្រាលកឋិន, កាលបើដូច្នេះ ហេតុអ្វីក៏ចាំឲ្យភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឲ្យអនុមោទនា?" ។

ឆ. (២) "អានិសង្សទាំង ៥ កើតមានដល់ភិក្ខុជាអ្នកក្រាលពិតមែន ប៉ុន្តែមិនកើតមានដល់សង្ឃឡើយ ព្រោះហេតុនោះ ទើបភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឲ្យអនុមោទនា ដើម្បីឲ្យអានិសង្ស ៥ កើតមានដល់សង្ឃផង ចំណែកសង្ឃក៏ត្រូវតែធ្វើអនុមោទនា កាលបើធ្វើយ៉ាងនេះ អានិសង្សទាំង ៥ ត្រូវកើតមានដល់បុគ្គលទាំងពីរពួក គឺភិក្ខុអ្នកក្រាល និងសង្ឃអ្នកអនុមោទនា" ។

គន្ថគម្ពីរបរិវារៈ មានសេចក្តីត្រូវគ្នាថា សង្ឃក្រាលកឋិនមិនបានទេ គណៈក៏ក្រាលកឋិនមិនបានទេ បុគ្គលទើបក្រាលកឋិនបាន ។ ដោយអនុមោ-

---

១ សហ កឋិនស្ស អត្ថារា បណ្ណរស ធម្មា ជាយន្តីតិ បរិវារេ អាគតត្តា កឋិនត្ថារេន សហេវ បញ្ច អានិសំសា អាគតា អថ កស្មា សង្ឃំ អនុមោទាបេតិ ។ ២ កិញ្ចាបិ អត្ថារកស្ស ភិក្ខុនោ បញ្ច អានិសំសា អាគតា សង្ឃស្ស បន អនាគតា តស្មា សង្ឃស្ស ច អាគមនត្ថំ សង្ឃំ អនុមោទាបេតិ សង្ឃោ ច អនុមោទន្តំ ករោតិ ឯវំ កតេ ឧភិន្នំបិ អានិសំសា អាគតា ។

ទនារបស់សង្ឃ ដោយអនុមោទនារបស់គណៈ និងដោយការក្រាលរបស់បុគ្គល, កឋិនឈ្មោះថាសង្ឃ គណៈ និងបុគ្គល បានក្រាលទាំងអស់គ្នា ។

## អំពីអានិសង្សលាភ

អដ្ឋកថា ប្រាប់ថា កាលបើភិក្ខុក្រាលកឋិនយ៉ាងនេះហើយ បើទាយកវេរប្រគេនសំពត់ជាអានិសង្សលាភ ដែលគេនាំមកជាមួយនឹងចីវរកឋិន ដោយពាក្យថា **យេន អម្ហាកំ កឋិនំ គហិតំ តស្សេវ ទេម** "កឋិនរបស់យើងខ្ញុំ លោកអង្គណា ទទួល យើងខ្ញុំសូមវេរប្រគេនចំពោះលោកអង្គនោះ" ដូច្នេះភិក្ខុសង្ឃមិនបានជាឥស្សរៈឡើយ បើលុះ-តែគេមិនបានចាត់ចែងដូច្នោះ គេគ្រាន់តែវេរប្រគេនហើយត្រឡប់ទៅផ្ទះវិញ ទើបភិក្ខុសង្ឃបានជាឥស្សរៈ ។ ព្រោះហេតុនោះ បើចីវរដ៏សេសទាំងប៉ុន្មានរបស់ភិក្ខុអ្នកក្រាលកឋិន ជាចីវរទុព្វលភាព ហើយសំពត់ជាអានិសង្សលាភរបស់កឋិនមានច្រើន (បើសង្ឃបានជាឥស្សរៈ) សង្ឃគប្បីអបលោកប្រគេនសំពត់បន្ថែមទៅលោកអ្នកក្រាលនោះទៀត ដើម្បីប្រ-**យោជន៍**ធ្វើចីវរទាំងនោះ, ប៉ុន្តែ ការសូត្រកម្មវាចាតែមួងក៏គួរហើយ ។ ឯសំពត់កឋិនានិសង្សលាភដែលសេសសល់ពីនោះ បើមានច្រើន ត្រូវចែកប្រគេនតាមបញ្ជីសំពត់ចំណាំវស្សា, បើមិនមានបញ្ជីទេ ត្រូវប្រគេនតាំងអំពីអាសនៈនៃព្រះថេរៈចុះមក, ឯគ្រឿងគរុភណ្ឌ មិនត្រូវចែកគ្នាឡើយ ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកបានពន្យល់អំពីការចែកអានិសង្ស-លាភ ឲ្យកាន់តែទូលាយឡើងទៀតថា(១) អកាលចីវរដែលសង្ឃតម្កល់ទុកក្នុងឃ្លាំង សង្ឃត្រូវបែងចំណែកពាក់កណ្ដាលចែកឲ្យសាមណេរទាំង-ឡាយ, ឯសំពត់ចំណាំវស្សា និងសំពត់ជាកឋិនានិសង្សជាដើម ដែលជាកាលចីវរ ក៏ត្រូវសង្ឃចែកឲ្យសាមណេរឲ្យស្មើគ្នានឹងភិក្ខុដែរ(២) ។

ពិធីក្រាលកឋិនចប់

---

## អនត្ថតាការ

អាការដែលភិក្ខុក្រាលមិនឡើងជាកឋិនឡើយ ហៅថា **អនត្ថតាការ** ។

សំ. កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការយ៉ាងណាខ្លះ ?

ឆ. តាមព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គថា កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការ ២៤ យ៉ាងគឺ

ទី ១– **ឧល្លិខិតមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់តែវាស់គូសក្រិតស្នួនមើលបណ្ដោយ-ទទឹងប៉ុណ្ណោះ ។

---

១ ភណ្ឌាគារេ បរិបតំ ហិ អកាលចីវរមេវ សាមណេរានំ ឧបឌ្ឍបដិវីសំ កត្វា ភាជេតុំ វស្សាវាសិកកឋិនានិសំសាទិកាលចីវរំ បន សមកមេវ ភាជេតុំ ។ ២ ចំពោះសាមណេរដែលបានចូលវស្សា, ឯសាមណេរដែលពុំបានចូលវស្សាទេ សង្ឃគួរសង្គ្រោះចែកឲ្យដោយអបលោកនកម្ម ឬបើមិនឲ្យសោះ ក៏ឥតមានកំហុសអ្វីឡើយ ។

ទី ២– **ធោវនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែល គ្រាន់តែបោកគក់លាង ។

ទី ៣– **ចីវរវិចារណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំ-ពត់ដែលគ្រាន់តែតាត់ថែងលៃលកទុកដាក់យ៉ាងនេះយ៉ាងនោះថា នេះជា ចីវរបញ្ចខណ្ឌ, នេះជាចីវរសត្តខណ្ឌ, នេះជាចីវរនវខណ្ឌ, នេះជាចីវរ ឯកាទសខណ្ឌ ។

ទី ៤– **ឆេទនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែល គ្រាន់តែកាត់តាមបែបដែលបានតាត់ថែងលៃលកទុក ។

ទី ៥– **ពន្ធនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលគ្រាន់-តែដានផ្គុំភ្ជាប់គ្នា ។

ទី ៦– **ឱវដ្ដិកករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំ-ពត់ដែលគ្រាន់តែដេរថ្នេរវែង ៗ ឬរង្វើល ៗ ។

ទី ៧– **កណ្ឌូសកករណមត្តេន** ភិក្ខុក្រាលកឋិន ដោយ សំពត់ដែលគ្រាន់តែភ្ជាប់ក្ដុំ និងក្រវិលក្ដុំ ។

ទី ៨– **ទឡ្ហីកម្មករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំ-ពត់ដែលគ្រាន់តែថែមសំពត់ ដើម្បីធ្វើឲ្យមាំ ។

ទី ៩– **អនុវាតករណមត្តេន** ភិក្ខុក្រាលកឋិន ដោយសំ-ពត់ដែលគ្រាន់តែលើកឡើង នូវអនុវាតខាងបណ្ដោយ ឬអនុវាតខាងខ្នង ។

ទី ១០– **បរិភណ្ឌករណមត្តេន** ភិក្ខុក្រាលកឋិន ដោយ សំពត់ដែលគ្រាន់តែលើកឡើង នូវអនុវាតខាងទទឹង ឬអនុវាតខាងពោះ ។

ទី ១១– **ឱវឌ្ឍេយ្យករណមត្តេន** ភិក្ខុក្រាលកឋិន ដោយ សំពត់ដែលគ្រាន់តែលើកបញ្ចូលផ្ទាំងសំពត់ថ្មី ពុំនោះគ្រាន់តែលើកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ទៅដាក់បញ្ចូលក្នុងកឋិនចីវរឯទៀត ។

ទី ១២– **កម្ពលមទ្ទនមត្តេន** ភិក្ខុក្រាលកឋិន ដោយសំពត់ ដែលគ្រាន់តែដាក់ចុះក្នុងទឹកជ្រលក់ ១ ដង មានពណ៌ដូចក្អកដំរី ឬស្លឹកឈើទុំលឿង ។

ទី ១៣– **និមិត្តកតេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលបាន មកដោយសារធ្វើនិមិត្តកម្ម គឺនិយាយបញ្ចៀតបញ្ចៀងថា "អាត្មានឹងក្រាលកឋិនដោយសំពត់បែបនេះ" ឬនិយាយថា "សំពត់សាដកនេះល្អ អាត្មាអាចនឹងក្រាលកឋិន ដោយសំពត់នេះបាន" ។

ទី ១៤ – **បរិកថាកតេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែល កើតឡើង ដោយសារការនិយាយបញ្ចុះបញ្ចូលទាយកថា "ការប្រគេន សំពត់កឋិន ជាការគួរ ព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងបាន ទទួលនូវផលបុណ្យដ៏ប្រសើរ" ។

អដ្ឋកថា ពន្យល់ថា ធម្មតាសំពត់កឋិន ទាល់តែឧក្រិដ្ឋណាស់ ទើប គួរ, ភិក្ខុនិយាយបញ្ចុះបញ្ចូល សូម្បីតែមាតារបស់ខ្លួន ក៏មិនគួរដែរ លុះ-

តែសំពត់នោះប្រាកដដូចជាធ្លាក់ចុះមកពីអាកាស ទើបគួរ ។

ទី ១៥– **កុក្កុកតេន** ភិក្ខុក្រាលកឋិន ដោយសំពត់ខ្ចីគេ ឬដោយសំពត់ដែលមិនមានទាយកនាំមកប្រគេន គឺសំពត់ស្វែងរកដោយខ្លួនឯង ។

ទី ១៦– **សន្និធិកតេន** ភិក្ខុក្រាលកឋិន ដោយសំពត់ដែលធ្វើឲ្យទៅជាសន្និធិ គឺទុកសំពត់នៅដៃសង្ឃ ឬនៅដៃនៃភិក្ខុអ្នកក្រាលឲ្យរំលងថ្ងៃ គឺមិនក្រាលឲ្យស្រេចក្នុងថ្ងៃនោះ ។

សន្និធិក្នុងអាការនេះមានពីរយ៉ាងគឺ ករណសន្និធិ ១ និចយសន្និធិ ១ ។ ការដែលភិក្ខុអ្នកក្រាលតម្កល់សំពត់កឋិនទុក មិនធ្វើឲ្យហើយក្នុងថ្ងៃនោះ ហៅថា ករណសន្និធិ ។ សង្ឃបានសំពត់កឋិនមកថ្ងៃនេះ ដល់ថ្ងៃស្អែក ទើបប្រគល់ឲ្យទៅភិក្ខុអ្នកក្រាល ហៅថា និចយសន្និធិ ។

ទី១៧ – **និស្សគ្គិយេន** ភិក្ខុក្រាលកឋិន ដោយចីវរជានិស្សគ្គិយៈ គឺចីវរកំពុងតែធ្វើទទួលអរុណរះឡើង ឬចីវរដែលកន្លងរាត្រី ។

ទី ១៨– **អកប្បកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើពិន្ទុកប្បៈ ។

ទី ១៩– **អញ្ញត្រ សង្ឃាដិយា** ភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីសង្ឃាដី មានសំពត់កម្រាលជាដើម ។

ទី ២០– **អញ្ញត្រ ឧត្តរាសង្គេន** ឬភិក្ខុក្រាលកឋិន ដោយសំពត់ក្រៅពីឧត្តរាសង្គៈ មានសំពត់កម្រាលជាដើម ។

ទី ២១– **អញ្ញត្រ អន្តរវាសកេន** ឬក៏ភិក្ខុក្រាលកឋិនដោយ
សំពត់ក្រៅពីអន្តរវាសកៈ មានសំពត់កម្រាលជាដើម ។

ទី ២២– **អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន** ភិក្ខុក្រាលកឋិនដោយ
ចីវរក្រៅពីចីវរដែលបានកាត់ជាបញ្ចខណ្ឌ ឬលើសពីបញ្ចខណ្ឌឡើងទៅ គឺ
សត្តខណ្ឌ, នវខណ្ឌ និង ឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយ
មណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌល ក្នុងថ្ងៃនោះឯង បានសេចក្តីថា
ក្រាលកឋិនដោយចីវរមិនបានប្រកបដោយលក្ខណៈត្រឹមត្រូវ មានមិនបាន
កាត់ជាបញ្ចខណ្ឌ (ដែលមានកន្ទ្រង់ធំ ៥ មានកន្ទ្រង់តូច ៥) ជាដើម ។

ក្នុងអាការនេះ គម្ពីរអដ្ឋកថា ដីកា បានអធិប្បាយសេចក្តីពិស្តារ
ដើម្បីឲ្យភិក្ខុសង្ឃងាយយល់ងាយប្រតិបត្តិតាម ដូចមានតទៅនេះ ៖

អដ្ឋកថា ប្រាប់ថា ការក្រាលកឋិន ដោយចីវរដែលបានធ្វើឲ្យត្រឹម-
ត្រូវ គឺបានកាត់ដាច់ជាបញ្ចខណ្ឌ ឬអតិរេកបញ្ចខណ្ឌ សម្តែងនូវមហា-
មណ្ឌល និងអឌ្ឍមណ្ឌល គឺកន្ទ្រង់ធំ និងកន្ទ្រង់តូច ឲ្យឃើញច្បាស់ ទើប
គួរ ។ មែនពិត, ចីវរដែលធ្វើយ៉ាងនេះ ឈ្មោះថា ធ្វើឲ្យប្រកបដោយ
មណ្ឌល បើភិក្ខុលើកលែងចីវរបែបនេះចេញ ហើយក្រាលដោយចីវរ
ដទៃទៀត ដែលមិនបានកាត់សោះក្តី កាត់តែត្រឹម ២ ខណ្ឌ, ៣ ខណ្ឌ,
៤ ខណ្ឌក្តី មិនគួរទេ ។

គម្ពីរធម្មសមូហវិន័យ ថា(១) កឋិនចីវរ ដោយកំណត់យ៉ាងហោចបំផុត ក៏ត្រូវឲ្យបានកាត់ស្បង់មួយដែរ បើធ្វើឲ្យខុសពីនេះ លោកចាត់ជា **អត្ថារវិបត្តិ** គឺក្រាលខុសមិនបានឡើងជាកឋិនឡើយ ព្រោះហេតុនោះ ចីវរកឋិន បើមិនបានកាត់ដេរឲ្យត្រឹមត្រូវ (ដូចស្បង់លាត ឬ ចីពរខុស សង្ឃាដីខុសជាដើម) មិនគួរទេ ។

ក្នុងគម្ពីរវជិរពុទ្ធិដីកាថា សំពត់កឋិន កាលបើសង្ឃសូត្រកម្មវាចា ប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាលហើយ ភិក្ខុអ្នកក្រាលត្រូវតែកាត់ធ្វើឲ្យប្រកបដោយមណ្ឌលត្រឹមត្រូវជាស្រេចក្នុងថ្ងៃនោះដែរ ។ ក៏ពាក្យដែលព្រះសង្គាហកត្ថេរ ពោលទុកក្នុងគម្ពីរបរិវារៈថា "បុព្វករណៈសង្គ្រោះដោយធម៌ ៧ ប្រការ" នោះ ចំពោះតែសំពត់ដែលសង្ឃប្រគល់ឲ្យមក នៅជាសំពត់ថ្មីសុទ្ធ គឺសំពត់មិនទាន់ធ្វើជាចីវរនៅឡើយ មិនមែនចំពោះចីវរដែលទាយកវេរប្រគេនមក ដោយបានធ្វើរួចស្រេចមកហើយនោះទេ ។ ព្រោះហេតុនោះ បើទាយកវេរប្រគេន នូវចីវរដែលធ្វើបុព្វករណៈរួចស្រេចមកហើយ សង្ឃត្រូវទទួលហើយសូត្រកម្មវាចា ប្រគល់ឲ្យទៅភិក្ខុអ្នកក្រាលចុះ ។ ឯភិក្ខុអ្នកក្រាលនោះ ត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះហើយញុំាងសង្ឃឲ្យអនុមោទនាចុះ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វករណៈ ដែលគេធ្វើរួចស្រេចមកហើយនោះថែមទៀតទេ ។ មែន-

---

១ សព្វន្តិមេន បរិច្ឆេទេន អន្តរវាសកោបិ ឆិន្នកោ វ កាតព្វោ អញ្ញថា អត្ថារវិបត្តិ ហោតិ តេនេវ អច្ឆិន្នសិព្វិតំ បន កឋិនំ ន វដ្តតិ ។

ពិត, ព្រះពុទ្ធដីកានៃព្រះពុទ្ធជាម្ចាស់ដែលព្រះអង្គត្រាស់ថា "ក្រាលកឋិនដោយសំពត់ដែលគ្រាន់តែកាត់គូស ក្រិតស្ទង់មើលទទឹងបណ្ដោយប៉ុណ្ណោះ មិនបានឡើងជាកឋិន" ជាដើមនោះ គឺសំដៅយកសំពត់ដែលមកដល់ដៃភិក្ខុអ្នកក្រាល នៅជាសំពត់ថ្មីសុទ្ធមិនទាន់ធ្វើជាចីវរនៅឡើយ ។

ក្នុងគម្ពីរធម្មសមូហវិន័យ និងគម្ពីរនិបុណ្ណបទសង្គហៈ មានសេចក្ដីបញ្ជាក់រឿងនេះ ដោយធ្វើជាពាក្យបុច្ឆា-វិស្សជ្ជនាដូចតទៅនេះ ៖

ស. [១] បើទាយកប្រគេនចីវរ ដែលមានបរិកម្មសម្រេចរួចហើយ ដើម្បីឲ្យភិក្ខុក្រាលកឋិន តើគួរ ឬមិនគួរ ?

ឆ. [២] អាចារ្យពួកខ្លះ ពោលថាមិនគួរ ព្រោះអាងព្រះពុទ្ធដីកាដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា **តទហេវ សញ្ឆិន្នេន** ដែលប្រែថា "ត្រូវកាត់ឲ្យហើយក្នុងថ្ងៃនោះ" ។

អ្នកសួរបដិសេធថា[៣]ពាក្យដែលអាចារ្យទាំងនោះពោលមិនគួរទេ ។

អ្នកឆ្លើយសួរតបវិញថា[៤]ហេតុដូចម្ដេចបានជាថាពាក្យនោះមិនគួរ ?

អ្នកសួរឆ្លើយថា[៥] បានជាថាពាក្យនោះមិនគួរ ព្រោះអាចារ្យទាំង-ឡាយដែលពោលមកនោះ មិនដឹងសេចក្ដីអធិប្បាយត្រង់បទថា **តទ.**

---

១ និដ្ឋិតបរិកម្មចីវរំ សចេ ទាយកោ កឋិនត្ថាយ ទេតិ វដ្ដតិ នុខោ ឧទាហុ ន វដ្ដតិ ។ ២ ឯកច្ចេ តទហេវ សញ្ឆិន្នេនាតិ វុត្តត្តា ន វដ្ដតីតិ វទន្តិ ។ ៣ តំ អយុត្តំ ។ ៤ កស្មា ។ ៥ តទហេវ សញ្ឆិន្នេនាតិ បទស្ស អធិប្បាយំ អជានិត្វា វុត្តត្តា ។ វិនយធរា បន បុញ្ញាចរិយា វដ្ដតីតិ វទន្តិ ។

**ហេច សញ្ឆិន្នេន** នោះឡើយ ឯបុព្វាចារ្យទាំងឡាយអ្នកទ្រទ្រង់វិន័យលោកពោលថាគួរ គឺចីវរកឋិនដែលគេធ្វើស្រេចហើយនោះ ពិតជាគួរ ។

ទី២៣– **អញ្ញត្រ បុគ្គលស្ស អត្ថារា** វៀរលែងការក្រាលរបស់បុគ្គល គឺមិនឲ្យបុគ្គលក្រាលត្រឡប់ជាឲ្យសង្ឃឬគណៈក្រាលវិញ ។

ទី២៤– **ន សម្មា ចេវ អត្ថតំ ហោតិ កឋិនំ និស្សីមដ្ឋោ អនុមោទតិ** បើភិក្ខុនៅក្រៅឧបចារសីមា អនុមោទនានូវកឋិនណា កឋិននោះ ឈ្មោះថា ក្រាលមិនត្រឹមត្រូវឡើយ ។

កឋិនដែលភិក្ខុក្រាលមិនឡើងជាកឋិន ដោយអាការ ២៤ នេះឯង ។

អនត្ថតាការ ចប់

## អត្ថតាការ

អាការដែលភិក្ខុក្រាលបានឡើងពេញលក្ខណៈជាកឋិន ហៅថា អត្ថតាការ ។

ស. កឋិនដែលភិក្ខុក្រាលឡើង ដោយអាការយ៉ាងណាខ្លះ ?

ឆ. តាមព្រះពុទ្ធដីកា ក្នុងគម្ពីរមហាវគ្គ ថា កឋិនដែលភិក្ខុក្រាលឡើង ដោយអាការ ១៧ គឺ

ទី ១ – **អហតេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ថ្មីសុទ្ធ គឺសំពត់ដែលគេមិនទាន់ប្រើ ។

ទី ២– **អហតកប្បេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលបោកគក់ ១ ដង ឬ ២ ដង ប្រាកដដូចជាសំពត់ថ្មីសុទ្ធ ។

ទី ៣– **បិលោតិកាយ** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់សាដកចាស់ ។

ទី ៤– **បំសុកូលេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់បង្សុកូល ដែលកើតឡើងក្នុងបង្សុកូលខេត្ត ២៣ ដែលគេយកមកវេរប្រគេន ។

ទី ៥– **អាបណិកេន** ភិក្ខុក្រាលកឋិន ដោយចីវរធ្វើដោយសំពត់ដែលធ្លាក់ចុះក្បែរទីផ្សារ ដែលទាយករើសយកមកវេរប្រគេន ។

ទី ៦– **អនិមិត្តកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបានធ្វើនិមិត្តកម្ម បញ្ចិតបញ្ចៀង ឲ្យទាយកគេវេរប្រគេនឡើយ ។

ទី ៧– **អបរិកថាកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលកើតឡើងដោយធម៌ គឺមិនបាននិយាយបញ្ចុះបញ្ចូលទាយក ឲ្យគេវេរប្រគេនឡើយ ។

ទី ៨– **អកុក្កុកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលទាយកគេវេរប្រគេន មិនមែនចីវរដែលខ្លួនខ្ចីគេឡើយ ។

ទី ៩– **អសន្និធិកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនបានធ្វើឲ្យជាសន្និធិ ។

ទី ១០– **អនិស្សគ្គិយេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលមិនមែនជានិស្សគ្គិយៈ ។

ទី ១១– **កប្បកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលបានធ្វើពិន្ទុកប្បៈរួចហើយ ។

ទី ១២– **សង្ឃាដិយា** ភិក្ខុក្រាលកឋិន ដោយសង្ឃាដី ។

ទី ១៣– **ឧត្តរាសង្គេន** ឬភិក្ខុក្រាលកឋិន ដោយឧត្តរាសង្គៈ ។

ទី ១៤– **អន្តរវាសកេន** ឬក៏ភិក្ខុក្រាលកឋិន ដោយអន្តរវាសកៈ ។

(អាការទី ១២ ទី ១៣ និងទី ១៤ នេះ មិនមែនត្រូវយកទាំង ៣ មកក្រាលកឋិនទេ ភិក្ខុអ្នកក្រាលត្រូវជ្រើសរើសយកតែ ១ មកក្រាល) ។

ទី ១៥– **បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលិកតេន** ភិក្ខុក្រាលកឋិន ដោយចីវរដែលបានកាត់ដាច់ជាបញ្ចខណ្ឌ ឬជាអតិរេកបញ្ចខណ្ឌ គឺសត្តខណ្ឌ, នវខណ្ឌ និងឯកាទសខណ្ឌ ព្រមទាំងធ្វើឲ្យប្រកបដោយមណ្ឌល គឺមហាមណ្ឌល និងអឌ្ឍមណ្ឌលឲ្យហើយស្រេចក្នុងថ្ងៃនោះ ។

ទី ១៦– **បុគ្គលស្ស អត្ថារា** មិនវៀរលែងអាការក្រាលរបស់បុគ្គល គឺភិក្ខុមួយរូបជាអ្នកក្រាល មិនមែនសង្ឃ ឬគណៈជាអ្នកក្រាលឡើយ ។

ទី ១៧– **សម្មា ចេ អត្ថតំ ហោតិ តញ្ចេ សីមដ្ឋោ អនុមោទតិ** បើភិក្ខុនៅក្នុងសីមា អនុមោទនាកឋិនណា កឋិននោះ ឈ្មោះថាក្រាលត្រឹមត្រូវ ។

កឋិនដែលភិក្ខុក្រាលឡើង ដោយអាការទាំង ១៧ នេះឯង ។

អត្ថារការ ចប់

---

## **ឧព្ភតកឋិន** «កឋិនដោះ»

ដំណើរកឋិនដោះនេះ ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាផ្ដើមឡើង ជាពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ, កឋិនដោះយ៉ាងណាខ្លះ ?

ព្រះពុទ្ធជាម្ចាស់ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលភិក្ខុទាំងឡាយ, មាតិកា ៨ នេះ ប្រព្រឹត្តទៅដើម្បីដោះនូវកឋិន ឬសម្រាប់កឋិនដោះ ។

សំ. ពាក្យថា "កឋិនដោះ" ហាក់ដូចជាកឋិនដោះខ្លួនចេញពីភិក្ខុ ព្រោះកឋិនកើតមានដល់ភិក្ខុ តាំងពីក្រាលរួចហើយ ។ គួរឲ្យឆ្ងល់ថា ហេតុដូចម្ដេចក៏កឋិនដោះខ្លួនចេញពីភិក្ខុ ? ឬក៏ពាក្យថា "កឋិនដោះ" បានសេចក្ដីដូចម្ដេចទៅវិញ ?

ឆ្លើ. ពាក្យថា "កឋិនដោះ" មិនមែនបានសេចក្ដីថា កឋិនរើដោះខ្លួនចេញពីភិក្ខុទេ ។ ពាក្យនេះបើពោលឲ្យពេញសេចក្ដី ត្រូវពោលថា កឋិនដែលភិក្ខុដោះចេញ ឬដកចេញ គឺភិក្ខុទេ ដែលជាអ្នកដោះ ឬ

ដកកឋិនចេញ ប៉ុន្តែដល់ពេលឲ្យខ្ទីទៅ នៅត្រឹមតែពាក្យថា "កឋិនដោះ" ប៉ុណ្ណោះ ។ រឿងកឋិនដោះនេះមានសេចក្ដីដូចតទៅនេះ ៖

ភិក្ខុបានក្រាល-អនុមោទនាកឋិនហើយក្នុងពេលណា ឈ្មោះថាមានកឋិនជាប់នៅនឹងខ្លួនក្នុងពេលនោះ កឋិននោះនាំឲ្យភិក្ខុមានអានិសង្ស ៥ ។ ការបង្កកឋិនឲ្យជាប់នៅនឹងភិក្ខុអ្នកក្រាល - អនុមោទនាដោយ **បលិពោធ** គឺកង្វល់ដែលទុកដូចជាចំណាង មានពីរយ៉ាង គឺ **អាវាស-បលិពោធ១ ចីវរបលិពោធ១** ។ ឯបលិពោធទាំងពីរយ៉ាងនេះ ជាប់នៅលើរូបភិក្ខុអ្នកក្រាល - អនុមោទនាគ្រប់រូប ។ កាលបើភិក្ខុអ្នកក្រាល-អនុមោទនាកឋិន ធ្វើឲ្យបលិពោធទាំងពីរដែលជាកង្វល់ទុកដូចជាចំណងជាប់ផុតចេញពីខ្លួនក្នុងពេលណា កឋិនក៏ដោះចេញ ឬឃ្លាតចេញពីភិក្ខុអ្នកក្រាល-អនុមោទនា ក្នុងពេលនោះដែរ ។ រឿងកឋិនដោះនេះនឹងមានសម្ដែងដោយសព្វគ្រប់ក្នុងមាតិកាទាំង ៨ ប្រការខាងមុខនេះ ប៉ុន្តែមាតិកាទាំង ៨ ប្រការនោះ មានការទាក់ទងនឹងបលិពោធទាំងពីរប្រការដោយជាក់ស្ដែង ហេតុនេះ គួរសម្ដែងនូវបលិពោធទាំងពីរជាមុន រួចសឹមសម្ដែងនូវមាតិកា ៨ តទៅ ដើម្បីឲ្យភិក្ខុអ្នកសិក្សាបានងាយយល់ដោយឆាប់រហ័ស ។

## បលិពោធ «កង្វល់»

ក្នុងគម្ពីរមហាវគ្គ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ, **បលិ-**

ពោធ (កង្វល់) របស់កឋិន មានពីរយ៉ាងគឺ

**១_ អាវាសបលិពោធ** "កង្វល់ចំពោះអាវាស" ។ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ នៅក្នុងអាវាសដែលបានក្រាល - អនុមោទនាកឋិននោះ មានសេចក្ដីអាល័យចំពោះអាវាសដែលខ្លួននៅនោះ, កាលបើចេញពីអាវាសនោះទៅ នៅមានបំណងថាអាត្មាអញនឹងត្រឡប់មកវិញ; យ៉ាងនេះ ហៅថា **អាវាសបលិពោធ** គឺភិក្ខុអ្នកក្រាល - អ្នកអនុមោទនាកឋិន នៅមានកង្វល់ក្នុងអាវាស ។

**២_ ចីវរបលិពោធ** "កង្វល់ចំពោះចីវរ" ។ សេចក្ដីថា ភិក្ខុក្នុងសាសនានេះ មិនទាន់បានធ្វើចីវរ ឬធ្វើមិនទាន់រួចស្រេចឬក៏សេចក្ដីប្រាថ្នាចំពោះចីវរមិនទាន់ដាច់នៅឡើយ; យ៉ាងនេះ ហៅថា **ចីវរបលិពោធ** គឺភិក្ខុអ្នកក្រាល - អ្នកអនុមោទនាកឋិន នៅមានកង្វល់ចំពោះចីវរ (ដែលត្រូវរក ឬដែលត្រូវធ្វើឲ្យមានគ្រប់គ្រាន់ល្មមប្រើប្រាស់បាន)(១) ។

## មាតិកា

ស. ពាក្យថា **មាតិកា** បានសេចក្ដីដូចម្ដេច ?

ឆ. តាមអដ្ឋកថា មានសេចក្ដីពន្យល់ថា **មាតិកា** គឺជាមាតាឬជាអ្នកបង្កើត ព្រោះមាតិកាទាំង៨នោះ ញុំាងកឋិនុទ្ធារៈ គឺការដោះកឋិនឲ្យកើត ។

---

១ ក្នុងសម័យយើងសព្វថ្ងៃនេះ ភិក្ខុទាំងឡាយច្រើនតែមានចីវរគ្រប់គ្រាន់ ពុំសូវខ្វះខាត ពុំសូវមានភិក្ខុដែលចេញពីវត្តលំនៅទៅរកចីវរទេ ដោយហេតុនេះ ពួកភិក្ខុច្រើនតែពុំសូវមានចីវរ-បលិពោធ នៅមានត្រឹមតែអាវាសបលិពោធប៉ុណ្ណោះឯង គួរភិក្ខុរក្សាអាវាសបលិពោធកុំឲ្យដាច់។

មាតិកា ៨ នោះ មានសេចក្ដីពន្យល់តទៅនេះគឺ

**១– បក្កមនន្តិកា** មាតិកា មានកិរិយាចៀសចេញទៅចាកកឋិនាវាស គឺអាវាសដែលក្រាល-អនុមោទនាកឋិន ជាទីបំផុត ឬជាកំណត់ ។ សេចក្ដីថា ភិក្ខុក្រាលកឋិន-អនុមោទនាកឋិនរួចហើយ នាំយកចីវរដែលធ្វើស្រេចហើយ ចេញទៅចាកអាវាស ដោយគិតថា " អាត្មាអញនឹងមិនត្រឡប់វិញទេ " ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះត្រង់ការចេញផុតចាកអាវាសជាកំណត់ ។ កឋិនដោះពេលណា អានិសង្ស ៥ របស់ភិក្ខុនោះ ក៏អស់ទៅក្នុងពេលនោះឯង ។

(ក្នុងមាតិកានេះចីវរបលិពោធដាច់មុន គឺដាច់តាំងពីនៅក្នុងអាវាស, អាវាសបលិពោធដាច់ក្រោយ) ។

**២– និដ្ឋានន្តិកា** មាតិកា មានកិរិយាសម្រេចនៃចីវរជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយនាំយកចីវរដែលមិនទាន់ធ្វើ ចេញទៅអំពីអាវាសដែលបានក្រាល បានអនុមោទនាកឋិន កាលដែលទៅដល់វត្តដទៃជិតខាង ជាវត្តនៅខាងក្រៅឧបចារសីមា ក៏មានគំនិតកើតឡើងថា "អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់វិញទេ" ។ ភិក្ខុនោះក៏បានធ្វើចីវរហើយស្រេចក្នុងទីនោះទៅ ។ គ្រាន់តែធ្វើចីវររួចស្រេចភ្លាម កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះក្នុងពេលដែលធ្វើចីវររួចស្រេចនុះឯង ។

(ក្នុងមាតិកានេះ អាពាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

**៣– សន្និដ្ឋានន្តិកា** មាតិកា មានសន្និដ្ឋានគឺសេចក្ដីសម្រេចចិត្តជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាលបានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសនោះទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមាក៏បានសម្រេចចិត្តថា "អញនឹងមិនរកគេឲ្យជួយធ្វើចីវរនេះទេ ទាំងវត្តដែលអាត្មាអញបានក្រាល បានអនុមោទនាកឋិន ក៏អញមិនត្រឡប់ទៅវិញឡើយ" ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រាដែលសម្រេចចិត្តនុះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធ និងចីវរបលិពោធ ដាច់ព្រមគ្នា)

**៤– នាសនន្តិកា** មាតិកា មានកិរិយាវិនាសចីវរជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ កាលទៅដល់វត្តជាខាងក្រៅឧបចារសីមា ក៏គិតថា "អញនឹងឲ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់ទៅកាន់វត្តដើមវិញទេ"; លុះកំពុងតែធ្វើ ចីវរនោះក៏ត្រូវវិនាសដោយហេតុណាមួយ មានចោរលួច ឬភ្លើងឆេះជាដើម ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះក្នុងគ្រាវិនាសចីវរ ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

**៥– សវនន្តិកា** មាតិកា មានកិរិយាឮដំណឹងជាទីបំផុត ។

សេចក្ដីថា ភិក្ខុបានក្រាល បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ ដោយគិតថា "អាត្មាអញនឹងត្រឡប់វិញ"; កាលទៅដល់វត្តជាខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរ លុះធ្វើចីវរហើយ ក៏បានឮដំណឹងថា "សង្ឃក្នុងវត្តស្រូតដោះកឋិនទៅហើយ" ។ កឋិនរបស់ភិក្ខុនោះឈ្មោះថាដោះក្នុងគ្រាដែលបានឮដំណឹងនុះឯង ។

(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)

**៦- អាសាវច្ឆេទិកា** មាតិកាប្រកបដោយកិរិយាដាច់បំណង ឬការអស់សេចក្ដីសង្ឃឹម ។ សេចក្ដីថា ភិក្ខុបានក្រាលកឋិន-បានអនុមោទនាកឋិនរួចហើយ ចេញពីអាវាសទៅដោយមានបំណងនឹងស្វែងរកចីវរក្នុងទីដទៃឯទៀត លុះទៅដល់ខាងក្រៅឧបចារសីមា ក៏គិតថា "អញនឹងស្វែងរកចីវរតែក្នុងទីខាងក្រៅឧបចារសីមានេះ អញនឹងមិនត្រឡប់ទៅវត្តវិញទេ"; ភិក្ខុនោះក៏ស្វែងរកចីវរក្នុងទីនោះ លុះដល់ស្វែងរកមិនបានបំណង ឬសេចក្ដីប្រាថ្នាក្នុងការស្វែងរកចីវរនោះ ក៏ដាច់ទៅ ឬអស់ទៅ ។ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលដាច់បំណង ឬអស់សេចក្ដីសង្ឃឹមក្នុងការស្វែងរកចីវរនុះឯង ។

(ក្នុងមាតិកានេះ អាវាសបលិពោធដាច់មុន ចីវរបលិពោធដាច់ក្រោយ)

**៧- សីមាតិក្កន្តិកា** មាតិកា មានកិរិយាកន្លងនូវសីមា គឺខេត្តនៃកឋិនជាទីបំផុត ។ សេចក្ដីថា ភិក្ខុបានក្រាល-បានអនុមោទនាកឋិន

រួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចេញពីអាវាសទៅ គិតថា "អញនឹងត្រឡប់មកវិញ"; លុះទៅដល់ខាងក្រៅឧបចារសីមា ក៏ឲ្យគេជួយធ្វើចីវរនោះ ។ កាលដែលធ្វើចីវររួចហើយ ក៏នៅតែគិតថា "អញនឹងត្រឡប់វិញ ៗ" ប៉ុន្តែមិនទាន់ត្រឡប់ ក៏បេះតែនៅខាងក្រៅឧបចារសីមានោះ ត្រាតែដល់កំណត់កាលដែលកឋិនដោះ គឺកន្លងហួសថ្ងៃ១៥កើតខែផល្គុណទៅ ។ កឋិនរបស់ភិក្ខុនោះ ក៏ដោះក្នុងគ្រាដែលកន្លងហួសសីមា គឺកន្លងហួសខែត្រនៃកឋិន ។

(ក្នុងមាតិកានេះ ចីវរបលិពោធដាច់មុន អាវាសបលិពោធដាច់ក្រោយ)

**៨_ សហុព្ភារា** មាតិកា មានការដោះកឋិនរួមជាមួយនឹងភិក្ខុទាំងឡាយ ។ សេចក្តីថា ភិក្ខុបានក្រាល-បានអនុមោទនាកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើ ចេញពីអាវាសទៅ គិតថា "អញនឹងត្រឡប់វិញ"; កាលទៅដល់ខាងក្រៅឧបចារសីមា ក៏បានឲ្យគេជួយធ្វើចីវរនោះ លុះធ្វើចីវររួចហើយ គិតថា "អញនឹងត្រឡប់វិញ ៗ" ហើយបានត្រឡប់មកទាន់ពេលដោះកឋិន ។ កឋិនរបស់ភិក្ខុនោះ ឈ្មោះថាដោះជាមួយនឹងភិក្ខុទាំងឡាយ ។

(ក្នុងមាតិកានេះ បលិពោធទាំងពីរដាច់ស្មើគ្នា មិនមុនមិនក្រោយ គឺដាច់ក្នុងពេលដែលចប់កម្មវាចា) ។

មាតិកា ៨ ចប់ដោយសង្ខេប

## កឋិនុព្ភារៈ «ការដោះកឋិន ឬកឋិនដោះ»

ស. *ការដោះកឋិន មានប៉ុន្មានយ៉ាង ?*

ឆ. *ក្នុងគម្ពីរវិនយាលង្ការដីកាថា*(១) *ការដោះកឋិនមានពីរយ៉ាងគឺ* អដ្ឋមាតិកាឧព្ភារៈ ១ អន្តរុព្ភារៈ ១ ។

ស. *ការដោះកឋិនទាំងពីរខាងលើនេះ មានសេចក្ដីដូចម្ដេច ហើយផ្សេងគ្នាយ៉ាងណាខ្លះ ?*

ឆ. *អដ្ឋមាតិកាឧព្ភារៈ ប្រែថា "ការដោះកឋិន ឬកឋិនដោះ តាមមាតិកា ៨" ។ សេចក្ដីអធិប្បាយថា ការដោះកឋិនតាមមាតិកា ៧ គឺ តាំងពី* បក្កមនន្តិកា *ដល់* សីមាតិក្កន្តិកា *នោះ លោកពោលសំដៅយកតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមា ហើយធ្វើឲ្យកឋិនដោះក្នុងទីនោះតែម្ដង ។ ឯការដោះកឋិនតាមមាតិកា ១ គឺ* សហុព្ភារៈ *នោះ គឺចំពោះតែភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមាដែរ ប៉ុន្តែត្រឡប់មកវិញទាន់ការដោះកឋិនក្នុងចន្លោះកាលកំណត់ ដែលហៅថា* អន្តរុព្ភារៈ *ក្នុងវត្តដែលខ្លួនបានក្រាល បានអនុមោទនាកឋិន ហើយបានធ្វើនូវការដោះកឋិននោះ រួមជាមួយនឹងភិក្ខុទាំងឡាយ, រួមជាមាតិកា ៨ ។ ការដោះកឋិនតាមមាតិកាទាំង ៨ នេះ ហៅថា* អដ្ឋមាតិកាឧព្ភារៈ ។

*រីឯ* អន្តរុព្ភារៈ *ប្រែថា "ការដោះកឋិនក្នុងចន្លោះកាលកំណត់" ។*

---

១ ឧព្ភារោ ទុវិធោ អដ្ឋមាតិកាឧព្ភារអន្តរុព្ភារវសេន ។

សេចក្ដីអធិប្បាយថា ការដោះកឋិន ដោយញត្តិទុតិយកម្មវាចា ដែលសម្រាប់សូត្រដោះកឋិន មិនចូលទៅក្នុងមាតិកា ៨ ទេ ហៅថា **អន្តរុព្ភារៈ** ព្រោះការដោះកឋិននោះ សម្រាប់តែភិក្ខុដែលមិនបានចេញទៅខាងក្រៅឧបចារសីមា គឺនៅតែក្នុងវត្តនោះ មិនទាន់ដល់កាលបរិច្ឆេទទេតែប្រជុំគ្នាធ្វើការដកកឋិនក្នុងចន្លោះកាលកំណត់ ។

ការដោះកឋិនទាំង ២ យ៉ាង គឺអដ្ឋមាតិកាឧព្ភារៈ និងអន្តរុព្ភារៈ មានសេចក្ដីផ្សេងគ្នាដូចអធិប្បាយខាងលើនេះ ។

ក្នុងគម្ពីរដែល មានសេចក្ដីបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតថា(១) អន្តរុព្ភារៈ និងសហុព្ភារៈទាំងពីរនេះ សង្ឃធ្វើដោយញត្តិទុតិយកម្មវាចា ។ ឯកឋិនុព្ភារៈ ៧ មានបក្កមនន្តិកាជាដើម ភិក្ខុមិនបានធ្វើដោយកម្មវាចាទេ ។

សំ. ការដោះកឋិន ២ យ៉ាងគឺ **អន្តរុព្ភារៈ** និង **សហុព្ភារៈ** មានសេចក្ដីប្លែកគ្នាដូចម្ដេច ?

ឆ. **អន្តរុព្ភារៈ** គឺភិក្ខុច្រើនរូប មិនបានចេញទៅខាងក្រៅឧបចារ-សីមាទេ ឋិតនៅតែខាងក្នុងឧបចារសីមាប្រជុំគ្នាធ្វើ ។ ឯ **សហុព្ភារៈ** គឺភិក្ខុមួយរូប ៗ ចេញទៅខាងក្រៅឧបចារសីមា ហើយត្រឡប់មកវិញទាន់អន្តរុព្ភារៈនោះ ហើយបានធ្វើជាមួយនឹងភិក្ខុទាំងឡាយ ដែលឋិតនៅក្នុង

---

១ អន្តរុព្ភារសហុព្ភារា ញត្តិទុតិយកម្មវាចាយេវ កតា បក្កមនន្តិកាទយោ សត្ត កឋិនុព្ភារា ន កម្មវាចាយ កតា ។

ឧបចារសីមានោះ ៗ នេះជាសេចក្ដីប្លែកគ្នានៃ **អន្តរាក្ការៈ និង សហាក្ការៈ** នោះ ៗ

ស. ភិក្ខុសង្ឃ ប្រជុំគ្នាសូត្រកម្មវាចាដោះកឋិន ក្នុងចន្លោះកាល គឺមិនទាន់ដល់កំណត់កាលនៃកឋិន តើដោយហេតុអ្វី ?

ឆ. ភិក្ខុសង្ឃ បានជាប្រជុំគ្នាសូត្រកម្មវាចាដោះកឋិនដូច្នេះ ដោយហេតុថាមានឧបាសកទាំងឡាយ មានបំណងនឹងធ្វើទានធំ ៗ ចង់ប្រគេនអកាលចីវរដល់ភិក្ខុទាំងឡាយ ដែលមិនបានក្រាល - អនុមោទនាកឋិន បាននិមន្តមកដល់ជាលំដាប់លំដោយហូរហែ គេសុំឲ្យព្រះភិក្ខុសង្ឃក្នុងកឋិនាវាសដកកឋិនចេញ ៗ (រឿងនេះព្រះពុទ្ធជាម្ចាស់ទ្រង់បានអនុញ្ញាតក្នុងភិក្ខុនីវិភង្គ ត្រង់សិក្ខាបទទី ១០ នៃនគ្គវគ្គ ដោយហេតុមានឧបាសកម្នាក់ ចង់ប្រគេននូវអកាលចីវរដល់ឧភតោសង្ឃ ហើយបានសូមព្រះភិក្ខុសង្ឃឲ្យដកកឋិនចេញ) ៗ

ដូច្នេះ ក្នុងវត្តនីមួយ ៗ កាលបើសង្ឃបានក្រាល-អនុមោទនាកឋិនហើយ សង្ឃលាភទាំងប៉ុន្មានដែលកើតឡើងក្នុងវត្ត ត្រូវតែចែកដល់សង្ឃដែលបានក្រាល-អនុមោទនាកឋិនទាំងនោះ មិនត្រូវចែកដល់សង្ឃដទៃឡើយ បើលុះតែផុតកាលនៃកឋិន គឺផុតពីថ្ងៃ ១៥ កើត ខែផល្គុណទៅ ឬបើមិនទាន់ផុតកាលនៃកឋិននៅឡើយទេ ប៉ុន្តែសង្ឃបានប្រជុំគ្នាសូត្រកម្មវាចាដកកឋិន ក្នុងចន្លោះកាលកឋិននោះ ទើបសង្ឃលាភដែលកើត

ឡើងក្នុងវត្តនោះ អាចនឹងចែករំលែកដល់ភិក្ខុសង្ឃឯទៀតៗបាន ។

រីឯពិធីសូត្រកម្មវាចាដកកឋិន ព្រះពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យភិក្ខុ ១ រូបដែលឈ្លាសប្រតិពល សូត្រប្រកាសសង្ឃ ដោយញត្តិទុតិយកម្មវាចា ថា ៖

**សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧទ្ធតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ការណ៍នេះ) បើជាការគួរដល់សង្ឃហើយ សង្ឃគួរដោះកឋិនចេញ ។ នេះជាពាក្យប្រកាសឲ្យសង្ឃបានជ្រាប ។ បពិត្រព្រះសង្ឃដ៏ចម្រើន, សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃដោះកឋិន ។ ការដោះកឋិន គួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកអ្នកមានអាយុអង្គណា លោកអ្នកមានអាយុអង្គនោះ ត្រូវនិយាយឡើង ។ កឋិនសង្ឃដោះហើយ ។ គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវការព្រមព្រៀងរបស់សង្ឃ ដោយអាការស្ងៀមយ៉ាងនេះ ។

កឋិនត្ថារៈ ចប់

# កឋិនភេទ «ប្រភេទនៃកឋិន»

ក្នុងគម្ពីរបរិវារៈ មានសេចក្ដីថ្លែងអំពីប្រភេទនៃកឋិន ពិស្ដារក្រៃពេកណាស់ ។ ខ្ញុំស្រង់យកនូវសេចក្ដីខ្លីៗ បន្តិចបន្តួច ពីគម្ពីរបរិវារៈនោះ ចំពោះតែត្រង់សេចក្ដីណាដែលមានប្រយោជន៍ ហើយជាសេចក្ដីងាយយល់ មកតម្កល់ទុកក្នុងទីនេះ ដើម្បីឲ្យយុវភិក្ខុ ងាយស្រួលក្នុងការសិក្សា ដូចមានតទៅនេះ ៖

ស. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មានប៉ុន្មានយ៉ាង?

ឆ. ធម៌ដែលកើតដំណាលគ្នានឹងការក្រាលកឋិន មាន ១៥ យ៉ាងគឺ មាតិកា ៨ បលិពោធ ២ និងអានិសង្ស ៥ ។ ទាំង ១៥ នេះ ហៅថា **សហជាតធម៌** ប្រែថា ធម៌កើតដំណាលគ្នា ឬកើតជាមួយគ្នា ។

ស. បុព្វករណៈ លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង ?

ឆ. បុព្វករណៈ លោកសង្គ្រោះដោយធម៌ ៧ យ៉ាង គឺ **ធោវនៈ** ការបោកគក់ ១ **វិចារណៈ** ការវាត់ចែងវាស់វែង ១ **ឆេទនៈ** ការកាត់ ១ **ពន្ធនៈ** ការដានផ្គុំ ១ **សិព្វនៈ** ការដេរ ១ **រជនៈ** ការជ្រលក់ ១ **កប្បករណៈ** ការធ្វើពិន្ទុកប្បៈ ១ ។

ស. បច្ចុទ្ធារៈ លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. បច្ចុទ្ធារៈ លោកសង្គ្រោះដោយរូបធម៌ ៣ យ៉ាងគឺ សង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

ស. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ប៉ុន្មានយ៉ាង ?

ឆ. អធិដ្ឋាន លោកសង្គ្រោះដោយរូបធម៌ ៣ យ៉ាងគឺ សង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១ ។

ស. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌ប៉ុន្មានយ៉ាង?

ឆ. អត្ថារៈ ការក្រាលកឋិន លោកសង្គ្រោះដោយធម៌តែ ១ យ៉ាង គឺវចីភេទ ការបញ្ចេញវាចា (ឲ្យសង្ឃបានត្រូវគ្រប់រូប) ។

ស. កឋិន មានមូលប៉ុន្មាន ? មានវត្ថុប៉ុន្មាន ? មានភូមិប៉ុន្មាន ?

ឆ. កឋិន មានមូល ១ គឺជុំនុំសង្ឃ; មានវត្ថុ ៣ គឺ សង្ឃាដី ១ ឧត្តរាសង្គៈ ១ អន្តរវាសកៈ ១; មានភូមិ ៦ គឺ ខោមៈ សំពត់ធ្វើដោយសរសៃសម្បកឈើ ១ កប្បាសិកៈ សំពត់ធ្វើដោយកប្បាស ១ កោសេយ្យៈ សំពត់ធ្វើដោយសូត្រ ១ កម្ពលៈ សំពត់ធ្វើដោយរោមសត្វ ១ សាណៈ សំពត់ធ្វើដោយសម្បកធ្មៃ ១ ភង្គៈ សំពត់ធ្វើដោយវត្ថុទាំង ៥ ខាងដើមលាយចម្រុះគ្នា ១ ។

ស. កឋិន មានអ្វីជាខាងដើម ? មានអ្វីជាកណ្តាល ? មានអ្វីជាខាងចុង ?

ឆ. កឋិន មានបុព្វករណៈជាខាងដើម; មានកិរិយា គឺបច្ចុទ្ធារ និងអធិដ្ឋាន ជាកណ្តាល; មានអត្ថារៈ ជាខាងចុង ។

ស. បុគ្គលប្រកបដោយអង្គប៉ុន្មាន មិនគួរក្រាលកឋិន ?

ឆ. បុគ្គលប្រកបដោយអង្គ ៨ មិនគួរក្រាលកឋិន ។ អង្គ ៨ នោះគឺ មិនចេះបុព្វករណៈ ១ មិនចេះបច្ចុទ្ធរៈ ១ មិនចេះអធិដ្ឋាន ១ មិនចេះក្រាល ១ មិនចេះមាតិកា ១ មិនចេះបលិពោធ ១ មិនចេះការដោះកឋិន ១ មិនចេះអានិសង្ស ១ រួមជា ៨ ។

ស. ចុះបុគ្គលប្រកបដោយអង្គប៉ុន្មាន ទើបគួរក្រាលកឋិន ?

ឆ. បុគ្គលប្រកបដោយអង្គ ៨ ដែរ ទើបគួរក្រាលកឋិន ។ អង្គ ៨ នោះគឺ ចេះបុព្វករណៈ ១ ចេះបច្ចុទ្ធរៈ ១ ចេះអធិដ្ឋាន ១ ចេះក្រាល ១ ចេះមាតិកា ១ ចេះបលិពោធ ១ ចេះការដោះកឋិន ១ ចេះអានិសង្ស ១ រួមជា ៨ ។

ស. ការក្រាលកឋិន របស់បុគ្គលប៉ុន្មានពួក មិនបានឡើងជាកឋិន? ប៉ុន្មានពួក ទើបឡើងជាកឋិន ?

ឆ. ការក្រាលកឋិន របស់បុគ្គល ៣ ពួក មិនបានឡើងជាកឋិនឡើយគឺ បុគ្គលឋិតនៅក្រៅឧបចារសីមាក្រាល - អនុមោទនាកឋិន ១ បុគ្គលក្រាល-អនុមោទនាកឋិន មិនបានបញ្ចេញវាចា ១ បុគ្គលកាលដែលបញ្ចេញវាចា មិនបានឲ្យអ្នកដទៃដឹងសេចក្តីច្បាស់ ១ ។

ការក្រាលកឋិន របស់បុគ្គល ៣ ពួក ក្រៅពីនេះទើបបានឡើងជាកឋិនគឺ បុគ្គលឋិតនៅក្នុងឧបចារសីមា ក្រាល-អនុមោទនាកឋិន ១ បុគ្គលកាលក្រាល-អនុមោទនាកឋិន បានបញ្ចេញវាចា ១ បុគ្គលកាលដែល

បញ្ចេញវាចា **បានឲ្យអ្នកដទៃដឹងសេចក្ដីច្បាស់ ១** ។

ស. **ការ**ក្រាលកឋិនប៉ុន្មានយ៉ាង មិនឡើងជាកឋិន ? ប៉ុន្មានយ៉ាង ទើបឡើងជាកឋិន ?

ឆ. ការក្រាលកឋិន ៣ យ៉ាង មិនឡើងជាកឋិនឡើយគឺ

**១. វត្ថុវិបន្ន** វត្ថុខុស បានដល់សំពត់កឋិនជាអកប្បិយៈ គឺចីវរមិនត្រឹមត្រូវ ។

**២. កាលវិបន្ន** កាលខុស បានដល់កាលដែលទាយកប្រគេនសំពត់ក្នុងថ្ងៃនេះ សង្ឃប្រគល់ឲ្យដល់ភិក្ខុអ្នកក្រាល ក្នុងថ្ងៃស្អែក ។

**៣. ករណវិបន្ន** ធ្វើខុស បានដល់ការមិនបានធ្វើសំពត់ដែលនៅថ្មីស្អុទ្ធ ឲ្យទៅជាចីវរត្រឹមត្រូវ ឲ្យទាន់ក្នុងថ្ងៃនោះ ។

ការក្រាលកឋិន ៣ យ៉ាងក្រៅពីនេះ ទើបបានឡើងជាកឋិនគឺ

**១. វត្ថុសម្បន្ន** វត្ថុត្រូវ បានដល់សំពត់កឋិនជាកប្បិយៈ គឺចីវរត្រឹមត្រូវ ។

**២ - កាលសម្បន្ន** កាលត្រូវ បានដល់កាលដែលទាយកប្រគេនសំពត់កឋិនក្នុងថ្ងៃណា សង្ឃបានប្រគល់ឲ្យភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ ។

**៣ - ករណសម្បន្ន** ធ្វើត្រូវ បានដល់ការធ្វើចីវរឲ្យបានត្រឹមត្រូវ ហើយទាន់ក្នុងថ្ងៃនោះ ប្រសិនបើសំពត់នោះជាសំពត់នៅថ្មីស្អុទ្ធនៅឡើយ ។ បើសំពត់ដែលទាយកប្រគេនមកនោះ គេបានធ្វើជាចីវរ

ត្រឹមត្រូវរួចស្រេចមកហើយ នោះមិនចាំបាច់ធ្វើអ្វីទៀតទេ ត្រូវតែបច្ចុទ្ធរ៍ អធិដ្ឋាន ក្រាល ឲ្យហើយស្រេចក្នុងថ្ងៃនោះ ក៏អាចចាត់ទុកជា ករណ-សម្បន្នពេញទី ។

ស. ខែណា ជាខែដែលត្រូវក្រាលកឋិន ?

ឆ. ខែ ១ ជាខាងចុងនៃវស្សានរដូវ គឺតាំងពីថ្ងៃ ១ រោច ខែអស្សុជ ទៅទល់នឹងថ្ងៃ ១៥ កើតខែកត្ដិក ជាខែដែលត្រូវក្រាលកឋិន ។

ស. ការក្រាលកឋិន ដែលជា **អត្ថាវិបត្តិ** "ក្រាលខុស" ឬជា **អត្ថាសម្បត្តិ** "ក្រាលត្រូវ" ត្រូវដឹងដោយអ្វី ?

ឆ. ការក្រាលកឋិន ជាអត្ថាវិបត្តិ ត្រូវដឹងដោយអនត្ថាការ ២៤; ដែលជាអត្ថាសម្បត្តិ ត្រូវដឹងដោយអត្ថាការ ១៧ ដែលបានពោលរួចមកហើយក្នុងខាងដើម ។

កឋិនកថាសង្ខេប

ចប់

រោងពុម្ព មិត្តភាព
កម្ពុជា-ជប៉ុន

តម្លៃ : ៧០០៛